ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education Youth and Sport

# កម្រងវិញ្ញាសា និងអត្រាកំណែ

## អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២

## ថ្នាក់វិទ្យាសាស្ត្រពិត និងសង្គម

### សម្រាប់ក្លិបសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រ

### ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

រៀបរៀង និងចងក្រងដោយៈ

ក្រុមនិស្សិតស្ម័គ្រចិត្តក្រសួងអប់រំ យុវជន និងកីឡា

ឆ្នាំសិក្សា ២០១៩- ២០២០

# អារម្ភកថា

សៀវភៅ «**កម្រងវិញ្ញាសាអក្សរសាស្ត្រខ្មែរ**» នេះ ជាស្នាដៃ ដែលក្រុមយើងខ្ញុំបានច្បិចយកតែមួយផ្នែក ក្នុងវិញ្ញាសាអក្សរសាស្ត្រខ្មែរនានាមកធ្វើការចងក្រងតែប៉ុណ្ណោះ ក្នុងគោលបំណងធ្វើឱ្យមានលក្ខណ:ងាយស្រួលដល់សិស្សក្នុងការសិក្សា និងអ្នកសិក្សាដែលចង់សិក្សាអំពីវិញ្ញាសាកន្លងមក។

ជាការពិតណាស់ ការសិក្សាពីវិញ្ញាសានានាដែលធ្លាប់ចេញ និងការសិក្សាពីកម្រងវិញ្ញាបន្ថែមពិតជាសារ:សំខាន់ណាស់ ដើម្បីជាជំនួយស្មារតីដល់សិស្សានុសិស្សគ្រប់រូបក្នុងការត្រៀមប្រឡងសញ្ញាបត្រទុតិយភូមិឱ្យទទួលបានជោគជ័យនៅពេលខាងមុខ។ ដោយសារមើលឃើញពីសារ:សំខាន់នៃការសិក្សាពីវិញ្ញាសាអក្សរសាស្ត្រខ្មែរបែបនេះហើយ ទើបធ្វើឱ្យក្រុមយើងខ្ញុំសម្រេចចិត្តចងក្រងសៀវភៅនេះឡើង។ ក្រុមយើងខ្ញុំក៏បានប្រមូលចងក្រងនូវរាល់វិញ្ញាសាមួយចំនួនរបស់ក្រសួងដែលធ្លាប់ចេញពីឆ្នាំ២០១៤ ដល់២០១៩ ទាំងថ្នាក់វិជ្ជាសាស្ត្រសង្គមនិងថ្នាក់វិទ្យាសាស្ត្រ អមជាមួយនឹងអត្រាកំណែរស្រាប់។លើសពីនេះក្រុមយើងខ្ញុំក៏បានបញ្ចូលនូវវិញ្ញាសាដៃទៀតដូចជាវិញ្ញាសាអក្សរសាស្ត្រខ្មែរសម្រាប់បើប្រាស់ក្នុងក្លឹបសិក្សាឆ្នាំ២០១៩ និងវិញ្ញាសាដែលបង្កើតឡើងដោយក្រុមនិស្សិតអក្សាសាស្ត្រខ្មែរសម្រាប់ប្រើប្រាស់ក្នុងក្លឹបសិក្សាឆ្នាំ២០១៩ដែលមានទាំងអត្រកំណែរ ផងដែរ។ សៀវភៅនេះ ក៏មិនមែនជាសៀវភៅដែលល្អឥតខ្ចោះនោះទេ តែក្រុមយើងខ្ញុំបានខិតខំប្រមូលយកឯកសារដែលពាក់ព័ន្ធមកដាក់ជាផ្នែកៗ បន្ថែមជាមួយនូវគំនិតថ្មីៗដែលទទួលបានពីនិស្សិតឯកទេសអក្សរសាស្ត្រនិងការចង្អុលបង្ហាញបន្ថែមពីលោកគ្រូ អ្នកគ្រូឯកទេស។ សមាជិកក្រុមទាំងអស់គ្នា បានខិតខំប្រឹងប្រែង តស៊ូព្យាយាម អស់ពីកម្លាំងកាយចិត្ត ទាំងយប់ទាំងថ្ងៃ ក្នុងការចងក្រង និងស្វែងរកឯកសាររហូតមក ទើបអាចធ្វើឱ្យស្នាដៃមួយនេះ បានប្រសូតលេចចេញជារូបរាងឡើងមក ដើម្បីទុកជាជំនួយបន្ថែមក្នុងការដឹកដៃសិស្សានុសិស្សឱ្យទទួលបានជោគជ័យនាពេលប្រលងខាងមុខ។

ជាចុងក្រោយ ក្រុមយើងខ្ញុំ ពិតជាមានចិត្តសោមនស្សរីករាយចំពោះការវាយតម្លៃ និងរិះគន់ដើម្បីជាស្ពានស្លាបនារកគំនិតអភិវឌ្ឍថ្មី ដែលជាមាគ៌ាបណ្ដុះវប្បធម៌ចែករំលែក និងការស្រឡាញ់ រួបរួមសាមគ្គីគ្នា ព្រោះហេតុថា រាល់ស្នាដៃចងក្រង បង្កើតនិងស្រាវជ្រាវទាំងអស់ទោះបីខិតខំប្រឹងប្រែងឱ្យបានល្អឥតខ្ចោះយ៉ាងណាក៏ដោយក្ដី ក៏នៅតែមិនអាចចៀសផុតពីកំហុសឆ្គងនានាបានឡើយ។ ដូច្នេះហើយ ក្រុមយើងខ្ញុំក៏សូមខន្តីអភ័យទោស ចំពោះមិត្តអ្នកអាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ពីគ្រប់មជ្ឈដ្ឋាន នូវរាល់កំហុសឆ្គងទាំងឡាយ ដែលបានកើតមានឡើង ដោយអចេតនាក្ដី ឬពុំបានត្រឹមត្រូវត្រង់ចំណុចណាមួយក្ដី ដោយធម៌អនុគ្រោះ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០

# សេចក្ដីថ្លែងអំណរគុណ

ជាដំបូង យើងខ្ញុំជាក្រុមនិស្សិតស្ម័គ្រចិត្ត ឯកទេសអក្សរសាស្ត្រខ្មែរ នៃក្រសួងអប់រំ យុវជន និងកីឡា ទាំងអស់គ្នា សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅក្រៃលែង និងពោរពេញដោយសេចក្ដីគោរព ចំពោះលោកអ្នកមានគុណទាំងទ្វេ ដែលបានផ្ដល់កំណើតឱ្យយើងខ្ញុំទាំងអស់គ្នា ហើយបានចំណាយរាល់សម្ភារៈ ការចិញ្ចឹមបីបាច់ថែរក្សា ផ្ដល់ជាពាក្យទូន្មានប្រៀនប្រដៅ ប្រកបដោយសេចក្ដីមេត្តាធម៌ចំពោះកូនៗ ជាពិសេសលោកបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដោយបានបញ្ជូនកូនៗទៅថ្នាលបណ្ដុះបណ្ដាល ដើម្បីឱ្យទទួលបានការអប់រំ រៀនសូត្រ មានចំណេះដឹង រហូតបានទទួលជោគជ័យនៅក្នុងជីវិត និងបានក្លាយជាធនធានមួយដ៏សំខាន់នៅក្នុងសង្គមជាតិរបស់ខ្លួន ហើយអាចបណ្ដុះធនធានថ្មីៗជាច្រើនទៀតបាន។

ជាកិច្ចបន្តទៀត យើងខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្ដមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រី និងថ្នាក់ដឹកនាំនៃក្រសួងអប់រំទាំងអស់ ដែលបានយកចិត្តទុកដាក់បង្កើតឱ្យមាន ក្លឹបសិក្សាឡើង ដើម្បីឆ្លៀតឱកាស ឱ្យនិស្សិតទាំងអស់អាចបង្កើនចំណេះដឹងពង្រឹងសមត្ថភាព និងអាចផ្ទេរបទពិសោធន៍ និងចែករំលែកនូវចំណេះដឹងមួយចំនួនដើម្បីជួពង្រឹងសមត្ថភាពសិស្ស ក្នុងវិទ្យាល័យទាំង៣នៃស្រុកកងមាសឱ្យទទួលបានជោគជ័យក្លាយជាធនធានមួយដ៏ខ្លាំងដែលអាចបណ្ដុះ និងជំរុញគ្រាប់ពូជជាច្រើនទៀតឱ្យបានចាក់ឫសចេញជាផ្លែផ្កា និងបានផ្ដល់ជាប្រយោជន៍ដល់សង្គមជាតិវិញ។

យើងខ្ញុំក៏សូមគោរពថ្លែងអំណរគុណចំពោះឯកឧត្ដមបណ្ឌិត **សាន វឌ្ឍនា** ដែលបានផ្ដល់ជាអនុសាសន៍ ទ្រឹស្ដី យោបល់ ការណែនាំ ដល់និស្សិតទាំងអស់ ឱ្យមានទុនក្នុងការធ្វើឱ្យដំណើរការក្លឹបទទួលបានជោគជ័យ ពីមួយឆ្នាំទៅមួយឆ្នាំ។

មួយវិញទៀត ក្រុមយើងខ្ញុំទាំងអស់គ្នា សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**លោកស្រី នៅ សុខម៉ាឌី** ដែលលោកស្រីបានជួយណែនាំ យកចិត្តទុកដាក់ ខិតខំអស់ទាំងកម្លាំងកាយចិត្ត ក្នុងការជួយផ្ដល់ជាគំនិតយោបល់ ជួយកែលម្អ តម្រែតម្រង់ផ្លូវលើដំណើរការក្លិបនេះ តាំងពីចាប់ផ្ដើម រហូតទទួលបានជោគជ័យ ដល់បានស្ថាបនាលេចចេញជារូបរាងសៀវភៅនេះឡើង។

បន្ថែមពីនេះក្រុមយើងខ្ញុំ សូមគោរពថ្លែងអំណរគុណ ចំពោះសាស្ត្រាចារ្យ គ្រូឧទ្ទេសទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានចែករំលែកនូវចំណេះដឹង និងដំបូន្មានល្អៗ ដល់យើងខ្ញុំទាំងអស់គ្នា ដើម្បីទុកជាមាគ៌ាមួយជួយយើងខ្ញុំទាំងអស់គ្នាឱ្យក្លាយជាក្រុម

និស្សិតដែលប្រកបដោយសមត្ថភាព សេចក្តីថ្លៃថ្នូរ និងជាទីគោរពស្រឡាញ់ពីសំណាក់សិស្សានុសិស្ស។

ជាចុងក្រោយក្រុមយើងខ្ញុំ សូមគោរពជូនពរចំពោះឯកឧត្តមបណ្ឌិតសភាចារ្យ ឯកឧត្តមបណ្ឌិត លោកស្រី ថ្នាក់ដឹកនាំ គ្រូឧទ្ទេសគ្រប់មុខវិជ្ជា និងអ្នកគ្រូលោកគ្រូទាំងអស់ដែលធ្លាប់បង្ហាត់បង្រៀនតាំងពីថ្នាក់តូចរហូតដល់ពេលនេះ ជួបប្រទះតែសេចក្តីសុខ ជោគជ័យគ្រប់ភារកិច្ចការងារ មានសុភមង្គល កម្លាំងពលំមាំមួន សុខសុវត្ថិភាពគ្រប់ទីកន្លែង ជាពិសេសជួបប្រទះពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ បីឃ្លៀតឃ្លាតឡើយ ។

ថ្ងៃព្រហស្បត្តិ៍ ៦កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០
ក្រុមអក្សរសាស្ត្រខ្មែរ!

# មាតិកា

ទំព័រ

អារម្ភកថា ........................................................................................................ I

សេចក្តីថ្លែងអំណរគុណ ...........................................................................................II

មាតិកា.............................................................................................................. III

**ជំពូក១៖ សេចក្តីផ្តើម**

១. សេចក្តីផ្តើម ....................................................................................................២

**ជំពូក២៖ វិញ្ញាសាក្រសួងអប់រំចេញប្រឡងឆ្នាំ២០១៤-២០១៩**

២.១.វិញ្ញាសាអក្សរសាស្ត្រខ្មែរថ្នាក់វិទ្យាសាស្ត្រ(២០១៤-២០១៩)..............................៤

២.២.វិញ្ញាសាថ្នាក់សង្គម(២០១៤-២០១៩)..............................................................២៦

**ជំពូក៣៖ វិញ្ញាសាត្រៀមប្រើប្រាស់ក្នុងក្លិប**

៣.១.វិញ្ញាសាត្រៀមឆ្នាំ២០១៨.....................................................................................៣៩

៣.២.វីញ្ញាសាត្រៀមប្រឡង២០២០...............................................................................៥៧

**ជំពូក៤៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**

៤.១.សេចក្តីសន្និដ្ឋាន.......................................................................................................៩៣

៤.២.សំណូមពរ............................................................................................................៩៤

ឯកសារយោង.........................................................................................................៩៥

# កម្រងវិញ្ញាសា៖ សំណេរតែងសេចក្តី

## ក្រុមនិស្សិតស្ម័គ្រចិត្តស្រុកកងមាស

## មុខវិជ្ជា៖ អក្សរសាស្ត្រខ្មែរ

### រៀបរៀងដោយនិស្សិត៖


១. កញ្ញា សុទ្ធ ស្រីនាង ២. លោក ហាប់ វណ្ណេត

៣.លោក អៀ គីមគៀង ៤.កញ្ញា ថៃ ស្រីម៉ាច

៥.កញ្ញា ឡុង សុផានីម ៦.កញ្ញា ឈឹម នីកា

៧.កញ្ញា នី សាវាន់ ៨.កញ្ញា ផាង គឹមអឿន

៩.លោក អ៊ុន ខួច ១០.កញ្ញា សៅ បូរ៉ាមី

១១.លោក ធន់ ដារ៉ា


## ឆ្នាំសិក្សា ២០១៩ - ២០២០

# ជំពូក១   សេចក្តីផ្តើម

មុខវិជ្ជាអក្សរសាស្ត្រខ្មែរ គឺជាមុខវិជ្ជាដ៏សំខាន់មួយសម្រាប់សិស្សានុសិស្សដែលកំពុងសិក្សានៅតាមវិទ្យាល័យនានាទូទាំងប្រទេសទាំងថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។ម៉្យាងវិញទៀតមុខវិជ្ជានេះក៏ជាមុខវិជ្ជាគោលមួយដែលក្រសួងតម្រូវឱ្យប្រឡងជារៀងរាល់ឆ្នាំ។ រាល់វិញ្ញាសាអក្សរសាស្ត្រខ្មែរសម្រាប់មធ្យមសិក្សាទាំងបឋមភូមិ និងទុតិយភូម ភាគច្រើនដកស្រង់ចេញពីកម្មវិធីសិក្សាដែលក្រសួងបានបញ្ចូលក្នុងសៀវភៅសិក្សាគោល។យើងមើលឃើញថា ការប្រឡងមានការរឹតបន្តឹងពីមួយឆ្នាំទៅមួយឆ្នាំខ្លាំងឡើងៗ ជាពិសេសកំណែទម្រង់លើការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីធានាឱ្យមានធនធានមនុស្សពិតប្រាកដស្របតាមគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ជាការពិតណាស់ការរឹតបន្តឹងនៃការប្រឡងគឺផ្តោតសំខាន់ទៅលើគ្រប់ផ្នែក ជាពិសេសគឺលើវិញ្ញាសាប្រឡងតែងតែមានការវិវត្តន៍ពីមួយឆ្នាំទៅមួយឆ្នាំក្រោមពាក្យស្លោក “អ្នកចេះគឺជាប់”។ដូច្នេះ ដើម្បីយកជាស្ពានចម្លង និងជាគំរូ បទពិសោធន៍ក្នុងការត្រៀមប្រឡង សិស្សានុសិស្សទាំងអស់តែងតែសិក្សាពីវិញ្ញាសាដែលក្រសួងធ្លាប់ចេញ និងវិញ្ញាសាថ្មីៗបន្ថែម ដើម្បីបង្កើនចំណេះដឹងបន្ថែមរបស់ពួកគេសម្រាប់ពេលប្រឡង។

ដោយមើលឃើញពីតម្រូវការ និងដើម្បីបង្ករភាពងាយស្រួលដល់សិស្សានុសិស្ស ក្រុមនិស្សិតស្ម័គ្រចិត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា ឯកទេសអក្សរសាស្ត្រខ្មែរយើងខ្ញុំបានខិតខំរួមគ្នាប្រមូល ចងក្រងនិងបង្កើតសៀវភៅនេះឡើង។គោលបំណងនៃការផលិតសៀវភៅនេះគឺធ្វើយ៉ាងណាផ្តល់ភាពងាយស្រួលដល់សិស្សានុសិស្ស ក្នុងការសិក្សានិងស្វែងយល់បន្ថែមពីវិញ្ញាសាអក្សរសាស្ត្រខ្មែរ ដោយក្រុមយើងខ្ញុំបានប្រមូលចងក្រងនូវវិញ្ញាសាអក្សរសាស្ត្រខ្មែរដែលក្រសួងធ្លាប់ចេញចាប់ពីឆ្នាំ ២០១៤ ដល់២០១៩ ប្រមជាមួយនឹងការបញ្ចូលបន្ថែមនូវវិញ្ញាសាដែលក្រុមនិស្សិតឆ្នាំមុនបានបង្កើតឡើង និងវិញ្ញាសាថ្មីៗដែលក្រុមយើងខ្ញុំរួមគ្នាផលិតឡើងសរុបប្រហែលជាសែសិបវិញ្ញាសាបូកនឹងអត្រាកំណែ។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមនិងរំពឹងទុកថាសៀវភៅមួយក្បាលដែលកំពុងនៅក្នុងដៃអ្នកទាំងអស់គ្នានេះ នឹងផ្តល់ជាគំនិត មតិយោបល់ ផ្តល់ចំណេះដឹងបន្ថែមដល់សិស្សានុសិស្ស អ្នកសិក្សាឱ្យទទួលបាននូវគំនិតទូលំទូលាយបន្ថែមទៀត។ យើងខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំថា អ្នកសិក្សា និងសិស្សានុសិស្សទាំងអស់ប្រើប្រាស់វាដើម្បីជាប្រយោជន៍ នឹងត្រៀមសម្រាប់ទទួលជោគជ័យនាពេលប្រឡងខាងមុខ។ ទន្ទឹមនឹងនេះដែរ ក្រុមនិស្សិតយើងខ្ញុំ ក៏រង់ចាំទទួលនូវមតិរិះគន់ដើម្បីស្ថាបនាជានិច្ច រាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនា ព្រមទាំងរង់ចាំ

ទទួលនូវការជួយបំពេញបន្ថែម លើចំណុចខ្វះខាតនានា ពីសិស្សានុសិស្ស និងអ្នកសិក្សាគ្រប់រូបផងដែរ។

ជាអវសាន យើងខ្ញុំសូមជូនពរអ្នកសិក្សាគ្រប់រូបឱ្យទទួលបានជោគជ័យ ពិសេសសិស្សានុសិស្សដែលកំពុងត្រៀមប្រឡងនាពេលខាងមុខសូមទទួលបានជោគជ័យ និងនិទ្ទេសល្អ គ្រប់ៗ គ្នា។

# ជំពូក២ វិញ្ញាសាក្រសួងអប់រំចេញប្រឡងឆ្នាំ២០១៤-២០១៩

## ២.១ វិញ្ញាសាថ្នាក់វិទ្យាសាស្ត្រ(២០១៤-២០១៩)

វិញ្ញាសា អក្សរសាស្ត្រខ្មែរ ថ្នាក់វិទ្យាសាស្ត្រ (២០១៤)

**ប្រធាន៖** មានទស្សនៈមួយថែងថា «អក្សរសិល្ប៍គឺជាកញ្ចក់សម្រាប់ឆ្លុះសង្គម»

ចូរអ្នកធ្វើការបកស្រាយទស្សនៈនេះដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់។

**<u>អត្រាកំណែ</u>**

**ក.សេចក្តីផ្តើម**

- លំនាំបញ្ហា៖
- ចំណូលបញ្ហា៖
- ចំណោទបញ្ហា៖ (ចោទតាមបែបពន្យល់)

**ខ.តួសេចក្តី**

- ឃ្លាភ្ជាប់+ពន្យល់ពាក្យ+ ពន្យល់ន័យ (៥ពិន្ទុ)
- ពន្យល់ពាក្យ (៥ពិន្ទុ)

**អក្សរសិល្ប៍៖** គឺជាកម្រងអត្ថបទដែលបានចងក្រងនូវរឿងរ៉ាវ រឺហេតុការណ៍ដែលបានកើតមានឡើងនៅក្នុងសង្គមប្រកបទៅដោយសិល្បៈវិធី។

**កញ្ចក់សម្រាប់ឆ្លុះសង្គម៖** ការធ្វើអោយឃើញពីអ្វីៗ។

- **ពន្យល់ន័យ៖** មតិរបស់ប្រធានចង់បង្ហាញឲ្យយើងបានដឹងថា តម្លៃនៃអត្ថបទទាំងឡាយដែលបានលើកយកមកបង្ហាញឲ្យឃើញពីអ្វីៗដែលបានកើតឡើងនៅក្នុងសង្គមនៃការរស់នៅរបស់មនុស្ស។
- បំណកស្រាយ (៤០ពិន្ទុ)

➢ អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងសង្គម»ដូចជាបានបង្ហាញឲ្យឃើញពីៈ

➢ របបគ្រប់គ្រងសង្គមតាមសម័យកាលនីមួយៗ(បង្ហាញឲ្យឃើញពីតថភាពសង្គម)

➢ ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសង្គម...

➢ ជំនឿ សាសនា ទំនៀមទម្លាប់ ប្រពៃណីក្នុងការរស់នៅ

➢ ទង្វើអយុត្តិធម៌ដែលកើតមានឡើងក្នុងសង្គម

- សកម្មភាពនៃការតស៊ូ ប្រឆាំងទៅនឹងខ្មាំងសត្រូវ ដើម្បីទាមទារសិទ្ធិសេរីភាពនិង ឯករាជ្យជាតិ។
- សកម្មភាពរបស់បុព្វបុរសក្នុងការចូលរួមចំណែក កសាង ការពារនិងអភិវឌ្ឍសង្គមអោយមានការរីកចម្រើន

លើកឧទាហរណ៍នៅក្នុងអក្សរសិល្ប៍ (២០ពិន្ទុ)

- .អក្សរសិល្ប៍ប្រជាប្រិយ

**រឿងធនសញ្ជ័យ**៖ បង្ហាញពីរបបរាជានិយមខ្មែរដែលទទួលរងការវាត
ទីពីបរទេស(ចិន) និងការតស៊ូរបស់បុព្វបុរសខ្មែរ ធ្វើការការពារទឹកដី
ស្ថិតស្ថេរ ឲ្យគង់វង្ស

**រឿងអ្នកតាទឹកអ្នកតាភ្នំ**៖ បានបង្ហាញពីសកម្មភាពរបស់បណ្តារប្រជា
ជនមួយចំនួនធំដែលមានគំនិតតស៊ូ ប្រឆាំងជាមួយនឹងធម្មជាតិ ក្នុងបំណងធ្វើម្ចាស់ទៅលើ
ធម្មជាតិ (អ្នកតាភ្នំជាតំណាង)

- អក្សរសិល្ប៍បុរាណ

**រឿងរាមកេរ្តិ៍**៖ បង្ហាញឲ្យឃើញពីទំនាស់ក្នុងការបែងចែកទ្រព្យ
សម្បត្តិ ការគោរពពាក្យសច្ចៈ (ពាក្យសត្យ) និងប្រពៃណីព្រះមហា
ក្សត្រ...

**រឿងទុំទាវ**៖ បានបង្ហាញឲ្យឃើញពីតថភាពសម័យលង្វែកដែលតែងនិយមប្រើអំណាចផ្តាច់ការ តាំងពីក្នុងសង្គមគ្រួសារ រហូតដល់សង្គម
ជាតិទាំងមូល

**+សង្គមគ្រួសារ**៖ មេគ្រួសារអនុវត្តទំនៀមទំលាប់ចាស់កំរិល បំបិទសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូរស្រករ ដល់បុត្រធីតារបស់
ខ្លួន ( នំមិនធំជាងនាឡិ)

**+សង្គមទាំងមូល**៖ អ្នកដែលមានអំណាចទ្រព្យសម្បត្តិ និងអំណាចយសសក្តិរមែងតែងប្រើអំណាចរបស់ខ្លួនក្នុងការគាបសង្កត់ វាយធ្វើបាបដល់អ្នកទន់ខ្សោយដោយមិនទទួលទោសពៃអ្វីឡើយ ដូចមានអរជូនជាដើម « ឧកញ្ញាអរជូនមាំមួនពេក ...កាប់ចាក់វាយដំពុំប្រណី»

**រឿងព្រះវេស្សន្តរ**៖ បានបង្ហាញឲ្យឃើញពីរបបគ្រប់គ្រងបែបលទ្ធិប្រជាធិបតេយ្យយកមតិរបស់ប្រជានុរាស្ត្រ ( បណ្តេញព្រះវេស្សន្តរតាមសំដីបណ្តារាស្ត្រ)

- អក្សរសិល្ប៍ទំនើប

**រឿងភូមិតិរច្ឆាន៖** បានបង្ហាញពិសេចក្តីទុក្ខដ៏សែនវេទនារបស់ប្រជារាស្ត្រខ្មែរ ដែលត្រូវបានរស់នៅស្ថិតនៅក្រោម ការត្រួតត្រា និងការប្រើអំណាចផ្តាច់ការរបស់ពួកអាណានិគមបារាំង តាមរូបភាពបារាំងបានធ្វើការបង្ខំខ្មែរឲ្យធ្វើការបង់ពន្ធគ្រប់មុខសព្វសារពើ....ក្រោយព្រឹត្តិការណ៍១៨មេសា១៩២៥...បានបង្ហាញពីសកម្មភាពតស៊ូរបស់ខ្មែរប្រឆាំងបារាំងដើម្បីបុព្វហេតុជាតិ

**រឿងគូលីកំនែន៖** អ្នកនិពន្ធបានបង្ហាញពីតថភាពពិតរបស់ប្រជាជនខ្មែរដែលរងការឈឺចាប់ដោយសារការគាបសង្កត់របស់ពួកសក្តិភូមិអាណានិគមបារាំង ជប៉ុន និងចក្រពត្តិអាមេរិក

- **សរុបមតិ** (៥ពិន្ទុ)

រួមសេចក្តីមក ស្របទៅតាមការអត្ថាធិប្បាយនិងឧទាហរណ៍ដូចដែល បានបញ្ជាក់យ៉ាងច្បាស់ទៅតាមរឿងនីមួយៗខាងលើយើងអាចនឹងដឹង បានថាអក្សរសិល្ប៍គឺពិតជាកញ្ចក់ឆ្លុះបញ្ចាំងតថភាពសង្គមខ្មែរយើងពិតប្រាកដមែន។

**<u>គ.សេចក្តីបញ្ចប់ </u>(៥ពិន្ទុ)**

- **វាយតម្លៃប្រធាន៖ (៣ពិន្ទុ)** ជាបញ្ចប់យើងអាចសន្និដ្ឋានបានថាមតិរបស់ប្រធាន ពិតជាមានតម្លៃនិងអត្ថន័យដ៏ល្អជ្រាលជ្រៅ សម្រាប់បង្ហាញឲ្យឃើញ ពីមុខងារ និងតម្លៃគ្រប់រឿងអក្សរសិល្ប៍ខ្មែរ ទាំងអស់ដែលអ្នកនិពន្ធ

បានតាក់តែងមក

- មតិផ្ទាល់ (២ពិន្ទុ) ដូចនេះ ...(ទស្សនៈផ្ទាល់របស់សិស្ស)។

*** សំគាល់៖** កិច្ចការសិស្សដែលបានលើករឿងអក្សរសិល្ប៍ផ្សេងៗដែលសមស្របក្រៅពីអត្រាកំណែ ត្រូវបានពិន្ទុដូចអត្រាកំណែ។ (ឧទាហរណ៍ក្នុងអក្សរសិល្ប៍យ៉ាងតិចបីរឿងទើបពិន្ទុពេញ

## វិញ្ញាសារៈ អក្សរសាស្ត្រខ្មែរ ថ្នាក់វិទ្យាសាស្ត្រ (២០១៥)

**ប្រធាន៖** សុភាសិតខ្មែរមួយចែងថា«ការងារជាមាសប្រាក់»

ចូរអ្នកបកស្រាយដោយរកអំណះអំណាងក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់។

<u>**អត្រាកំណែ**</u>

**ក.សេចក្តីផ្តើម៖ (ពិន្ទុ)**

- **លំនាំបញ្ហា៖** មនុស្សទាំងឡាយរមែងចង់បាននូវទ្រព្យសម្បត្តិមាសពេជ្រ កែវកង...(៤ពិន្ទុ)
- **ចំណូលបញ្ហា៖** ដើម្បីសម្រេចតាមបំណងប្រាថ្នានេះបានលុះត្រាតែយើង ខិតខំស្វះស្វែងរកការងារត្រឹមត្រូវ បានធ្វើជាប្រចាំ ហេតុដូចនេះហើយបានជាមានសុភាសិតមួពោលថា «ការងារជាមាសប្រាក់»
(៣ពិន្ទុ)
- **ចំណោទបញ្ហា៖** តើសុភាសិតខាងលើនេះមានអត្ថន័យដូចម្តេច? (ចោទបែបពន្យល់) (៣ពិន្ទុ)

**ខ.តួសេចក្តី៖**

**-ឃ្លាភ្ជាប់+ពន្យល់ពាក្យ** (៣ពិន្ទុ)

- ការងារ៖ កិច្ចការប្រកបមុខរបរ ចិញ្ចឹមជីវិត
- មាសប្រាក់៖ លុយកាក់ទ្រព្យសម្បត្តិមាសពេជ្រកែវកងទាំងឡាយ

- **ពន្យល់ន័យប្រធាន៖**

មតិរបស់ប្រធានមានន័យថាកិច្ចការងារទាំងឡាយដែលជាមុខរបរចិញ្ចឹមជីវិតដោយមានភាពត្រឹមត្រូវពិតជាទ្រព្យសម្បត្តិលុយកាក់មាសពេជ្រកែវកងដែលជាទីតម្រូវការរបស់មនុស្សយើង។

- **បំណកស្រាយ** (៤០ពិន្ទុ)

ការងារនៅទីនេះគឺសំដៅទៅលើការងារទាំងឡាយណាដែលមានភាពត្រឹមត្រូវ សុចរិតទៀងត្រង់សមស្របទៅតាមច្បាប់ និងមិនធ្វើឲ្យ
ប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកដទៃឡើយ។

➢ ការងារទាំងនោះមានដូចជា:

- រូបភាពការងារទូទៅក្នុងជីវភាព( ៥ពិន្ទុ)

-ការងារពាណិជ្ជករះ រកស៊ីទទួលទានដើម្បីផលចំណេញ

-ការងារកសិករះ ការងារធ្វើស្រែចំការដើម្បីទទួលបានទិន្នផល

-ការងារកម្មករះ ការងារដោយប្រើកម្លាំងបាយដើម្បីប្រាក់កំរៃ

-ការងារឧស្សាហករ សិប្បករះ ជាការងារច្នៃប្រឌិតបង្កើតជាសម្ភារៈឬ ឧបករណ៍ប្រើប្រាស់ជាទីតម្រូវការរបស់មនុស្សយើង។

-កិច្ចការងារមន្ត្រីរាជការ...

- លក្ខណៈការងារដែលទទួលបាននូវតម្លៃល្អៗសម្រាប់ជីវិតមនុស្សៈ (៧ពិន្ទុ)

-មានភាពសុចរិតត្រឹមត្រូវសមស្រប តាមទស្សនៈវិស័យរបស់មនុស្ស និងសង្គមជាតិ។

-មានការតស៊ូព្យាយាម ឈ្លាសវៃប៉ុិនប្រសប់មានគំនិតច្នៃប្រឌិតខ្ពស់

-កាងារមានមនសិការប្រកបទៅដោយការត្រិះរិះពិចារណាខ្ពស់

-ការងារប្រកបទៅដោយក្រមសីលធម៌ខ្ពស់ចេះអធ្យាស្រ័យ គោរពច្បាប់

-ការងារបម្រើមនុស្សជាតិនិងប្រទេសជាតិ...

»ផលល្អ និងផលប្រយោជន៍ះ (៨ពិន្ទុ)

-ទទួលបានប្រាក់កម្រៃជាអចិន្ត្រៃសម្រាប់យកទៅផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ

-សេដ្ឋកិច្ចគ្រួសារមានការរីកចម្រើនរុងរឿងជាលំដាប់

-ជីវភាពគ្រួសារមានស្ថេរភាពយូរអង្វែង

-មនុស្សយើងមានកេរ្តិ៍ឈ្មោះ ល្បាញល្បីទទួលការគោរពពីអ្នកដទៃ

-មានភាពឧត្តុងឧត្តមក្នុងជីវិត

-គ្រួសារទទួលបានក្តីសុខ សុភមង្គលគ្រប់ពេលវេលា

-សង្គមជាតិក៏ទទួលបានសុខសន្តិភាពនិងការអភិវឌ្ឍគ្រប់ផ្នែកវិស័យ

- អំណះអំណាង( លើករឿងអក្សរសិល្ប៍មកបញ្ជាក់បីរឿង)(២០ពិន្ទុ)

. **រឿងកូលាបប៉ៃលិនះ** អ្នកនិពន្ធញ៉ុកថែមរៀបរាប់ពីសកម្មភាពរបស់ចៅចិត្រខិតខំបំពេញកិច្ចការងារជូនលោករតនសម្បត្តិប្រកបទៅដោយ

ភាពត្រឹមត្រូវសុចរិតទៀងត្រង់ជាហេតុធ្វើអោយលោករតនៈសម្បត្តិពេញចិត្តបានលើកយកថៅចិត្រធ្វើជាកូនប្រសាររបស់លោកដែលធ្វើឲ្យជីវិតថៅចិត្រទទួលបានពន្លឺសុភមង្គលដ៏ត្រចះត្រចង់។

. **រឿងព្រះអាទិត្យថ្មីរះនៅលើផែនដីចាស់**៖ លោករដ្ឋមន្ត្រីខិតខំធ្វើការជាតិ...ធ្វើឲ្យជីវិត កេរ្តិ៍ឈ្មោះរបស់លោកទទួលបានការគោរពពី

**រឿងទុំទាវ** ៖ អ្នកនិពន្ធ ភិក្ខុសោម ខ្សែជីវិតរបស់ទុំ និងពេជ្រដែលខិតខំសិក្សាវិជ្ជាជីវៈធ្វើតោក សិល្បៈតន្ត្រី រហូតព្រះរាជារាមាជើងព្រៃតែងតាំងជាមុឺនឯកខាងបច្ចេកទេស កិច្ចការងារសិល្បៈតន្ត្រីប្រចាំរាជវាំង។

**រឿងគូលីកំណែន**៖ ម៉ឹងខិតខំសិក្សារៀនសូត្រ ក្លាយទៅជាមន្ត្រីរាជការ..

. **រឿងថៅកែចិត្តចោរ** ៖ពូហាំប្រកបការងារមិនល្អក៏ទទួលបានកេរ្តិ៍ឈ្មោះមិនល្អ ជាប់គុក .

**រឿងមាយើង**៖ ប្រឹងប្រែងតស៊ូក្នុងកិច្ចការងារល្អ ទៅជាអ្នកមានទ្រព្យ

***បញ្ជាក់៖**សិស្សអាចលើករឿងផ្សេងៗមកបញ្ជាក់ក៏បានឲ្យតែបានបីរឿងតែអត្ថន័យរឿងសមស្របទៅតាមខ្លឹមសារប្រធាន។

- **សរុបមតិ (៥ពិន្ទុ**)

សរុបសេចក្តីមកស្របទៅតាមការស្រាយបំភ្លឺនិងឧទាហរណ៍ដូចដែលបានបញ្ជាក់ខាងលើយើងអាចដឹងបានថា ការងារពិតជាមាសប្រាក់ពិតប្រាកដមែនពីព្រោះថាលុយកាក់ទ្រព្យសម្បត្តិទាំងឡាយពិតជាបានកើតមានឡើងដោយការប្រកបកិច្ចការទាំងអស់ បើពុំនោះសោតទេយើងមិនអាចទទួលបានលុយកាក់មាសពេជ្រកែវកងបានឡើយ។

**គ សេចក្តីបញ្ចប់**_(១០ពិន្ទុ)

- **វាយតម្លៃ** (៦ពិន្ទុ)

ជាបញ្ចប់ឆ្លងទៅតាមការអត្ថាធិប្បាយស្រាយបំភ្លឺខាងលើយើងសន្និដ្ឋានបានថាមតិរបស់ប្រធានពិតជាមានអត្ថន័យនិងតម្លៃដ៏ល្អជ្រាលជ្រៅបំផុតដែលបានបង្ហាញឲ្យយើងបានដឹងយ៉ាងច្បាស់ អំពីកិច្ចការទាំង

ឡាយគឺពិតជានាំអោយកើតមានទ្រព្យសម្បត្តិមាសពេជ្រកែវកងជា

ប្រាកដ។

- **មតិផ្ទាល់** (៤ពិន្ទុ)

ដូចនេះក្នុងនាមយើងជាមនុស្ស ម្នាក់ៗដើម្បីទទួលបាននូវទ្រព្យ

សម្បត្តិលុយកាក់មាសពេជ្រកែវកង ពោលគេត្រូវខិតខំរិះរកកិច្ចការ
ងារប្រកបអោយបានអចិន្ត្រៃបើពុំនោះសោតទេលុយកាក់នឹងមិនអាចកើតមានឡើយ។

**<u>របៀបដាក់ពិន្ទុ</u>**

ក សេចក្តីផ្តើម

- លំនាំះ  (៤ពិន្ទុ)
- ចំណូលះ (៣ពិន្ទុ)
- ចំណោទះ(៣ពិន្ទុ )

ខ តួសេចក្តី

- ឃ្លាភ្ជាប់+ពន្យលពាក្យះ (៣ពិន្ទុ)
- ពន្យល់ន័យះ (២ពិន្ទុ)
- បំណកស្រាយះ (៤០ពិន្ទុ)
  - បកស្រាយគំនិតសំខាន់ (២០ពិន្ទុ)
  - អំណះអំណាង (២០ពិន្ទុ)
- សរុបមតិ (៤ពិន្ទុ)

គ បញ្ចប់សេចក្តី

- វាយតម្លៃ (៦ពិន្ទុ)
- មតិផ្ទាល់ (៤ពិន្ទុ)
- រចនាបថ (៥ពិន្ទុ

## វិញ្ញាសា អក្សរសាស្ត្រខ្មែរ ថ្នាក់វិទ្យាសាស្ត្រ (២០១៦)

**ប្រធានៈ** មានមតិមួយពោលថា« អត្ថបទអក្សរសិល្ប៍មានគោលដៅអប់រំមនុស្សឬឲ្យចេះដោះស្រាយបញ្ហា»

ចូរអ្នកបកស្រាយដោយយកឧទាហរណ៍ក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់។

<u>**អត្រាកំណែ**</u>

**ក.សេចក្តីផ្តើមៈ** (១០ពិន្ទុ)

- លំនាំបញ្ហាៈ (៤ពិន្ទុ)
- ចំណូលបញ្ហាៈ (៣ពិន្ទុ)
- ចំណោទបញ្ហាៈ ចោទបែបពន្យល់ (៣ពិន្ទុ)

**ខ.តួសេចក្តី**

- ឃ្លាភ្ជាប់+ពន្យល់ពាក្យ
- ឃ្លាភ្ជាប់ៈ (១ពិន្ទុ )
- ពន្យល់ពាក្យៈ(ពិន្ទុ)

-អក្សរសិល្ប៍ៈ កម្រងអត្ថបទដែលតុបតែងដោយអក្សរប្រកបទៅដោយសិល្បវិធីរឿងទាំងឡាយដែលតាក់តែងឡើងប្រកបទៅដោយសិល្បវិធី។

-គោលដៅៈ អ្វីដែលផ្តុំហើយសំដៅរក ឬតម្រង់ទៅរក

-អប់រំៈ ហ្វឹកហាត់ កែលម្អឲ្យប្រពៃ (ធ្វើឲ្យល្អ)

-បញ្ហាៈ ពាក្យ រឺ សេចក្តីដែលមានអាថ៌កំបាំង ប្រស្នា ឬចំណោទ

- ពន្យល់ន័យៈ (២ពិន្ទុ)

ទស្សនៈប្រធានមានន័យថាកម្រងអត្ថបទរឿងដែលអ្នកនិពន្ធតាក់តែងឡើងសុទ្ធសឹងផ្តុំទៅដោយខ្លឹមសារល្អៗតម្រង់ទៅរកការហ្វឹកហាត់កែលម្អដោយជួយឲ្យមនុស្សចេះដោះស្រាយអាថ៌កំបាំងនានាដែលមនុស្សបានជួប...

- បកស្រាយ (៤០ពិន្ទុ)

១. កម្រងអត្ថបទអក្សរសិល្ប៍មានគោលដៅអប់រំមនុស្សឲ្យចេះដោះស្រាយបញ្ហា

+អក្សរសិល្ប៍បានបង្ហាញបញ្ហាដែលមនុស្សជួបប្រទះជាច្រើនដូចជាៈ

»បញ្ហាសង្គម

-បញ្ហា ភាពក្រីក្រ

-បញ្ហាសុភមង្គល

-បញ្ហាសិទ្ធិសេរីភាព -បញ្ហា ជិះជាន់

-បញ្ហា កេងប្រវ័ញ្ច

-បញ្ហាទាក់ទងវប្បធម៌ អរិយធម៌

»បញ្ហាធម្មជាតិ

-បញ្ហាទឹកជំនាន់

-គ្រោះធម្មជាតិ

២. ការដែលអក្សរសិល្ប៍ លើកបញ្ហាទាំងអស់មកបង្ហាញមានគោលដៅអប់រំមនុស្សឲ្យចេះដោះស្រាយបញ្ហាដូចជា៖ (១០ពិន្ទុ)

-មានប្រាជ្ញាឈ្លាសវៃ

-មិនប្រើហិង្សា

-ចេះតស៊ូ

-ឧស្សាព្យាយាម

-អង់អាចក្លាហាន

-ត្រិះរិះ ពិចារណា វិភាគ

-ពិសេសគម្រូល្អៗក្នុងអក្សរសិល្ប៍ត្រូវទទួលយកចំណុចអាក្រក់ អវិជ្ជមានគួរជៀសវាង។

៣. លើកឧទាហរណ៍ក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ

»អក្សរសិល្ប៍ប្រជាប្រិយ៖ (៦ពិន្ទុ)

-រឿងអ្នកតាទឹកអ្នកតាភ្នំ៖ បង្ហាញបញ្ហាទឹកជំនន់

+ផ្តល់គំនិតអប់រំឲ្យដោះស្រាយបញ្ហាទឹកជំនន់

-រឿងធនសញ្ជ័យ៖ បង្ហាញពីបញ្ហាការកេងប្រវ័ញ្ចការប្រើអំណាចផ្តាច់ការ

+ការដោះស្រាយដោយប្រើបញ្ញា ប្រាជ្ញាវៃឆ្លាត

-រឿងកំណើតរន្ទះ...

»អក្សរសិល្ប៍បុរាណ (ពិន្ទុ)

-រឿងព្រះវេស្សន្តរ

-រឿងរាមកេរ្តិ៍

-រឿងពុទ្ធិសែន...

»អក្សរសិល្ប៍សម័យទំនើប (៧ពិន្ទុ)

-រឿងភូមិតិរច្ឆាន

-រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ -រឿងគូលីកំណែន

**-សរុបមតិ៖** (៥ពិន្ទុ)

សរុបសេចក្តីមកអក្សរសិល្ប៍ពិតជាមានគោលដៅអប់រំមនុស្សឲ្យចេះដោះស្រាយបញ្ហាមែនព្រោះគ្រប់ស្នាដៃអក្សរសិល្ប៍ខ្មែរទាំងបីចលនាបង្ហាញពីបញ្ហាហើយយកបញ្ហាទាំងនោះមកជាគំនិតដល់យើងឲ្យចេះដោះស្រាយបញ្ហាក្នុងជីវភាព និងសង្គមបាន។

**គ.បញ្ចប់សេចក្តី** (ពិន្ទុ)

-វាយតម្លៃប្រធាន៖  ប្រធានមានអត្ថន័យល្អ បង្ហាញអោយយើងឃើញតួនាទីសំខាន់របស់អក្សរសិល្ប៍ដែលរួមចំណែកដល់ការអប់រំមនុស្ស និងសង្គម។

-មតិផ្ទាល់៖ ដូចនេះអក្សរសិល្ប៍មិនគ្រាន់តែអាចកំសាន្តសប្បាយប៉ុណ្ណោះទេ ថែមទាំងបានចូលរួមចំណែកផ្តល់នូវការអប់រំដល់មនុស្សនិងសង្គម... (អាស្រ័យលើសិស្ស)

*សំគាល់

. ពន្យល់ពាក្យចាប់ពីពីរឡើងទៅឲ្យពេញ

លើឧទាហរណ៍៖ ចាប់ពីបីឡើងទៅអ្វីក៏បានអោយពេញ

## ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង ២១ សីហា ២០១៧

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ (ថ្នាក់វិទ្យាសាស្ត្រ)

## រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥

**ប្រធាន៖** "ការសិក្សាពេញមួយជីវិតគឺជារបៀបនៃការអប់រំក្នុងសតវត្សទី២១"

ចូរធ្វើការអធិប្បាយពន្យល់ទស្សនៈខាងលើនេះដោយលើកទាហរណ៍មកបញ្ជាក់

**អត្រាកំណែ**

**១.ផ្ដើមសេចក្ដី**

- **លំនាំបញ្ហា៖** មនុស្សទូទៅទោះបីជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ ដើម្បីរៀបចំដំណើរជីវិតឲ្យកាន់តែប្រសើរឡើងចាំបាច់ត្រូវឆ្លងកាត់ការសិក្សារៀនសូត្រចំណេះដឹងឱ្យបានទូលំទូលាយខ្ពង់ខ្ពស់...។
- **ចំណូលបញ្ហា៖** ដោយហេតុនេះហើយទើបមានការលើកជាប្រធានបទ..."ការសិក្សាពេញមួយជីវិតគឺជារបៀបនៃការអប់រំក្នុងសតវត្សទី២១" ។
- **ចំណោទបញ្ហា៖** តើប្រធានបទលើកឡើងនេះមានខ្លឹមសារបែបណា?

២. តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី៖** មុននឹងធ្វើការបកស្រាយប្រធានបទលើកឡើងនេះ ឲ្យប្រកបដោយភាពច្បាស់លាស់គ្រប់គ្រាន់ន័យសេចក្ដី..............។
- **ពន្យល់ពាក្យ៖**

•ការសិក្សា៖ ការស្រាវជ្រាវ រៀនសូត្រ ការស្វែងរកចំណេះដឹង បទពិសោធ....

•របៀប៖ វិធី មធ្យោបាយ ឬយន្តការប្រព្រឹត្តទៅ។

•អប់រំ៖ ការទូន្មានប្រៀនប្រដៅ ឲ្យប្រព្រឹត្តអំពើល្អត្រឹមត្រូវ។

•សវត្សទី២១៖ យុគសម័យដែលកំពុងដំណើរការបច្ចុប្បន្ន ពេលសព្វថ្ងៃ។

- **ពន្យល់ន័យ៖** ន័យរបស់ប្រធានគឺបកស្រាយជុំវិញការសិក្សាស្រាវជ្រាវរៀនសូត្រ ចំណេះដឹងដ៏យូរអង្វែងគឺជាការអប់រំទូន្មានប្រៀនប្រដៅរបស់មនុស្សនៅក្នុងយុគ សម័យបច្ចុប្បន្ន ដើម្បីឲ្យក្លាយទៅជាធនធានមនុស្សដ៏ល្អ។
- **បកស្រាយ៖**

•គំនិតសំខាន់៖ ការសិក្សាពេញមួយជីវិតគឺជារបៀបនៃការអប់រំក្នុងសតវត្សទី២១។

•សេចក្តីលម្អិត៖

លក្ខណៈនៃការសិក្សា៖ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបាននូវចំណេះវិជ្ជា ជ្រៅជ្រះ លុះត្រាតែអនុវត្តទៅតាមគោលការណ៍៖

+ចេះសិក្សារៀនសូត្រតាមក្បួនច្បាប់ គម្ពីរ ទ្រឹស្តី រូបមន្ត ក៏ដូចជាតាមរយៈកម្រងសៀវភៅ នានាជាច្រើនព្រោះវាជាចំណែកសំខាន់សម្រាប់ផ្ទេរចំណេះដឹងដល់មនុស្សទូទៅដែលចង់ចេះ ដឹង។

+ចេះអនុវត្តតាមអង្គ៤គឺ សុ ចិ បុ លិ

សុ៖ ការយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់

ចិ៖ ការគិតពិចារណាលើខ្លឹមសារមេរៀន

បុ៖ ចេះឆ្ងល់ ចេះសួរគ្រូ

លិ៖ ការចេះកាត់ត្រាមេរៀន

+ចេះសិក្សាស្រាវជ្រាវតាមបណ្តាញប្រព័ន្ធបច្ចេកវិទ្យាទាន់សម័យ...។

លទ្ធផលនៃការសិក្សា៖ “ការសិក្សាពេញមួយជីវិតគឺជារបៀបនៃការសិក្សាជារបៀបនៃការ អប់រំក្នុងសតវត្សទី ២១”៖

+ធ្វើឲ្យទទួលបានជំនាញផ្សេងៗសម្រាប់យកទៅប្រកបរបរចិញ្ចឹមជីវិត

+មានចំណេះដឹងខាងភាសាអន្តរជាតិ

+មានចំណេះដឹងជុំវិញលេខនព្វន្តសម្រាប់យកទៅប្រើប្រាស់

+មានបំណិនខាងបច្ចេកវិទ្យាស្របទៅតាមយុគសម័យថ្មី

+មានបំណិនក្នុងការដោះស្រាយបញ្ហាដែលកើតឡើងក្នុងសង្គម(គ្រួសារ សង្គមជាតិ)

+ចេះគិតពិចារណាអ្វីដែលល្អ អាក្រក់...

+មានចំណេះដឹងលើផ្នែកវប្បធម៌ ដោយចេះថែរក្សាវប្បធម៌ជាតិ ចេះធ្វើសំយោគវប្បធម៌បរទេស+.....................................។

**ឧទាហរណ៍៖**

+ក្នុងសង្គម៖

-សម្តេចសង្ឃរាជ ជួន ណាត លោកបានសិក្សាពេញមួយជីវិតទាក់ទងទៅនឹងអក្សរសាស្ត្រជាតិ រហូតអាចបង្កើតបានជាសៀវភៅ ក្បួនច្បាប់ តម្រា វចនានុក្រម អក្សរសាស្ត្រជាតិ បន្សល់ទុកអោយកូនចៅខ្មែរគ្រប់ៗជំនាន់បានស្រាវជ្រាវរៀន សិក្សាសូត្រ...។

-ក្នុងពេលបច្ចុប្បន្ននេះ៖ មានមនុស្សច្រើនណាស់ដែលបានប្រើពេលវេលាសិក្សាពេញមួយជីវិត ទៅលើចំណេះជំនាញផ្សេងៗ ហើយគេក៏អាចបំពេញបាននូវតម្រូវការចាំបាច់ក្នុងជីវិតសង្គមជាក់ស្តែង ស្របទៅតាមការវិវត្តនៃរបបសង្គមក៏ដូចជាការរីកចម្រើននៃបច្ចេកទេសវិទ្យាសាស្ត្រ.....។

+ក្នុងអក្សរសិល្ប៍៖

-រឿងកុលាបប៉ៃលិន៖ តួអង្គចៅចិត្រ បានប្រើពេលវេលារៀនសូត្រយូរអង្វែង ទាំងចំណេះដឹងសកល ទាំងអសកល ធ្វើឲ្យចៅចិត្រទទួលបាននូវចំណេះដឹងខាងលេខនព្វន្តក្បួនច្បាប់ មានជំនាញខាងជួសជុល មានជំនាញលើមុខរបរជីកត្បូង ចេះភាសាបារាំង យល់ដឹងពីប្រវត្តិសាស្ត្របារាំង...។

-រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖ តាមរយ:តួអង្គរដ្ឋមន្ត្រីក្មេង បានបន្តវិជ្ជារៀនសូត្របានខ្ពង់ខ្ពស់ ទាំងក្នុង និងក្រៅប្រទេស ធ្វើឲ្យទទួលបាននូវចំណេះដឹងទូលំទូលាយ មានទាំងជំនាញបច្ចេកទេស ពេលបញ្ចប់ការសិក្សាត្រឡប់មកស្រុកវិញ ក៏ត្រូវបានរាជការជ្រើសរើសតាំងជារដ្ឋមន្ត្រីទាំងវ័យក្មេង មិនត្រឹមតែបានរៀនសូត្រខ្ពង់ខ្ពស់មានចំណេះដឹងមានឋានៈតួនាទីប៉ុណ្ណោះទេ តែយុវជនរូបនេះ ដោយបានសិក្សារៀនសូត្រជ្រៅជ្រះទើបមានគំនិតទូលាយប្រកាន់ខ្ជាប់នូវតម្លៃមនុស្សធម៌ សីលធម៌ ការរស់នៅ សិទ្ធិសេរីភាព...

-រឿងតេជោយ៉ត៖ តួអង្គតេជោយ៉ត ប្រើពេលវេលាសិក្សាពេញមួយជីវិតទាំងចំណេះដឹងសកល ទាំងចំណេះដឹងអសកល ពោល គឺគេបានយកចិត្តទុកដាក់រៀនសូត្រលេខនព្វន្ត អក្សរសាស្ត្រ ក្បួនច្បាប់ យុទ្ធសាស្ត្រចម្បាំង រហូតទទួលបានភាពស្ទាត់ជំនាញក្នុងការធ្វើសឹកសង្គ្រាម ឈ្នះគ្រប់សមរភូមិមានប្រាជ្ញាឈ្លាសវៃ ចេះដោះស្រាយបញ្ហាខ្លួនឯងនិងប្រទេសជាតិបានប្រសើរ ចេះរៀបចំជីវិតរស់នៅប្រកបដោយកិត្តិយសសេចក្តីថ្លៃថ្នូរ ភាពល្បីល្បាញ...។

រឿងថៅកែចិត្តចោរ៖ តួអង្គផានីតចាកចេញពីស្រុកកំណើតមកបន្តការសិក្សានៅភ្នំពេញដើម្បីស្វែងរកចំណេះវិជ្ជាខ្ពង់ខ្ពស់។ ទោះបីជាស្នាក់អាស្រ័យជាមួយនឹងញាតិសន្តានក៏សុខចិត្តទ្រាំរស់ទាំងមិនមានសិទ្ធិសេរីភាពភាពគ្រប់គ្រាន់...។ ទោះបីជាត្រូវប្រឡងធ្លាក់ក៏នៅតែតស៊ូរៀនសូត្រពោលគឺរៀនបណ្តើរធ្វើការបណ្តើរដើម្បីទទួលបាននូវចំណេះជំនាញពិតប្រាកដ។ ដោយសារការរៀនសូត្រនេះទើបផានីតអាចមានលទ្ធភាពជាងពួកកម្មករឯទៀត គឺជាជំនួយការ ស្មៀនរបស់ថៅកែ ចេះបូកបញ្ជី ចេះបូកលុយ កាន□់កាប់កិច្ចការចំណូលចំណាយ ថៅកែទុកចិត្តឲ្យកាន់ការងារនេះ...។

**៥.សរុបមតិ ៖**

សរុបសេចក្តីមកអាចនិយាយបានថា ការសិក្សាទោះបីជាសិក្សាលើចំណេះដឹងសកល ឬចំណេះដឹងអសកលគឺលើជំនាញបច្ចេកទេសក៏ពុទ្ធិទាំងនោះបានក្លាយជាចំណែកសំខាន់សម្រាប់មនុស្សទូទៅ ក្នុងការរៀបចំការរស់នៅរបស់ខ្លួនឲ្យបានប្រសើរក្នុងសង្គមមិនថាមិនមិនថាបច្ចុប្បន្នឬទៅអនាគតនោះទេ។ ការរៀនសូត្រនៅតឬបន្តរហូតមិនចេះចប់ ទើបទទួលបាននូវអ្វីដែលប្លែក ថ្មី អាចបំពេញតម្រូវការក្នុងការរស់នៅបាន...។

**៣.បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន៖** ផ្អែកតាមការបកស្រាយប្រធានបទលើកឡើងខាងលើរួចមក អាចសន្និដ្ឋានបានថា ការលើកឡើងនៃប្រធានបទខាងលើនេះ មានសារៈសំខាន់ ផ្តល់នូវគុណតម្លៃដ៏ប្រសើរ ព្រោះបានបង្ហាញអោយឃើញពីតម្លៃនៃវិជ្ជាសម្រាប់មនុស្សទូទៅដែលត្រូវតែសិក្សាពេញមួយជីវិត...។

- **មតិផ្ទាល់ខ្លួន៖** ដូចនេះដើម្បីរៀបចំការរស់នៅក្នុងបច្ចុប្បន្នឲ្យប្រសើរសមស្របទៅតាមយុគសម័យថ្មីនៃការរីកចម្រើនលើបច្ចេកទេសវិទ្យាសាស្ត្រ ការសិក្សាពេញមួយជីវិតគឺជារបៀបនៃការរស់នៅរបស់មនុស្សសម័យថ្មី...។

❖ **រចនាបថ**

ការប្រើប្រាស់អក្ខរាវិរុទ្ធ និងវេយ្យាករណ៍បានត្រឹមត្រូវ ទម្រង់តែងមានរបៀបរៀបរយល្អ ហើយអក្សរស្អាត។

## ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ២០ សីហា ២០១៨

## វិញ្ញាសាៈ អក្សរសាស្ត្រខ្មែរ (ថ្នាក់វិទ្យាសាស្ត្រ)

## រយៈពេលៈ ៩០នាទី ពិន្ទុ ៧៥

ប្រធានៈ ពាក្យចាស់លោកពោលថា "សេចក្ដីព្យាយាមគង់បានសម្រេច"

ចូរបកស្រាយដោយយកអំណះអំណាងក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់។

អត្រាកំណែ

**១.សេចក្ដីផ្ដើម**

- **លំនាំបញ្ហាៈ**

មនុស្សគ្រប់រូបរមែងចង់បានសម្រេចគ្រប់កិច្ចការទាំងឡាយដែលខ្លួនបំពេញជារៀងរាល់ថ្ងៃនោះ ដើម្បីសម្រេចតាមបំណងនេះបុគ្គលនីមួយៗតែងតែខិតខំប្រឹងប្រែងការងារនោះដោយជម្នះគ្រប់ការលំបាកចំពោះមុខ។

- **ចំណូលបញ្ហាៈ**

ដោយមានបំណងអបរំឲ្យកូូនចៅចេះតស៊ូប្រឹងប្រែងបំពេញកិច្ចការដូចខាងលើនេះហើយទើបមានពាក្យចាស់មួយឃ្លាពោលថា"សេចក្ដីព្យាយាមគង់បានសម្រេច"។

- **ចំណោទបញ្ហាៈ**

តើពំនោលខាងលើនេះមានន័យដូចម្ដេច?

**២.តួសេចក្ដី**

- **ឃ្លាភ្ជាប់សេចក្ដីៈ**
- **ពន្យល់ពាក្យៈ**

•សេចក្ដីព្យាយាមៈ សេចក្ដីប្រឹងប្រែងការប្រឹងប្រែងដំណើរខ្មីឃ្មាត,

•សម្រេចៈ ធ្វើឲ្យដាច់ស្រេចធ្វើឲ្យកើតការធ្វើឱ្យបានការឲ្យសមស្របទៅតាមបំណង

- **ពន្យល់ន័យៈ**

មតិរបស់ប្រធានមានន័យថាសេចក្ដីខំប្រឹងប្រែងគឺគង់តែបានធ្វើឱ្យកើតការបានសម្រេចសមតាមបំណងប្រាថ្នា

- **បំណកស្រាយ៖**

•គំនិតសំខាន់"សេចក្ដីព្យាយាមគង់បានសម្រេច"

•សេចក្ដីលម្អិត

•ប្រភេទនៃសេចក្ដីព្យាយាម

-ព្យាយាមរៀនសូត្រ

-ព្យាយាមធ្វើការងារប្រកបមុខរបរចិញ្ចឹមជីវិត

-ព្យាយាមដោះស្រាយបញ្ហាដែលបានកើតឡើង

-ជម្នះរាល់បញ្ហាគ្រប់ឧបសគ្គ

-ព្យាយាមក្នុងការតស៊ូប្រឆាំងគ្រោះធម្មជាតិ

-ព្យាយាមលុបបំបាត់នៃការរើសអើង

-ព្យាយាមតស៊ូកម្ចាត់សត្រូវ

-ព្យាយាមក្នុងការធ្វើទង្វើល្អ ត្រឹមត្រូវតាមរយៈផ្លូវ កាយ វាចា ចិត្ត

-ព្យាយាមគោរពច្បាប់របស់ប្រទេស

-ព្យាយាមស្វែងរកសេក្ដីយុត្តិធម៌

- ...( សិស្សអាចលើកគំនិតសំខាន់ផ្សេងៗពីនេះបាន )

• លក្ខណៈនៃការព្យាយាម

-ដោយសុចរិតយុត្តិធម៌

- ដោយតស៊ូ អំណត់ អត់ធ្មត់

-ប្រើអស់កម្លាំងកាយចិត្ត

-ដោយគំនិត សុទិដ្ឋិនិយម

-ដោយភាពជឿជាក់

-ដោយមានការកំណត់គោលដៅច្បាស់លាស់

-ដោយមានសីលធម៌ល្អ

-...(សិស្សអាចលើកគំនិតសំខាន់ផ្សេងៗពីនេះបាន)

• អត្ថប្រយោជន៍នៃការព្យាយាម

-ទទួលជោគជ័យលើការងារដែលបានធ្វើទាំងអស់

-កំណត់គោលដៅបានទៅតាមសេចក្ដីប្រាថ្នា

-ដឹកនាំមនុស្សឆ្ពោះទៅរកសេចក្ដីសុខសុភមង្គល

-ប្រទេសមានការអភិវឌ្ឍន៍រីកចម្រើនគ្រប់ផ្នែកវិស័យឆ

• អំណះអំណាងក្នុងរឿងអក្សរសិល្ប៍ត្រូវលើករឿងអក្សរសិល្ប៍៣រឿង÷

**១.រឿងកុលាបប៉ៃលិន៖** អ្នកនិពន្ធលោក ញ៉ុក ថែម បានលើកយកមកបង្ហាញឲ្យឃើញពីសកម្មភាពរបស់ចៅចិត្រដែលបានព្យាយាមតស៊ូសិក្សារៀនសូត្ររហូតទទួលបានចំណេះដឹងខ្ពង់ខ្ពស់បានព្យាយាមប្រព្រឹត្តទង្វើល្អ តាមរយៈផ្លូវកាយ វាចា ចិត្ត គួបផ្សំនឹងមានទឹកចិត្តភក្ដីភាពជាមួយចៅហ្វាយនាយរបស់ខ្លួន ជាហេតុធ្វើឱ្យលោកហ្លួងរតនសម្បត្តិពេញចិត្តបានលើកយកចៅចិត្តធ្វើជាកូនប្រសាររបស់លោក ជាហេតុធ្វើឲ្យចៅចិត្រទទួលបានសុភមង្គលក្នុងជីវិត។

**២.រឿងទុំទាវ៖** អ្នកនិពន្ធ ភិក្ខុ សោមបានរៀបរាប់ឱ្យឃើញពីសកម្មភាពរបស់នេនទុំ នេនពេជ្រដែលបានព្យាយាមសិក្សារៀនសូត្រ តាមរយៈផ្លូវធម៌ ផ្លូវលោក រៀនមុខវិជ្ជាជីវៈ ចេញធ្វើគោកចេះផ្លុំប៉ី ចេះស្មូត្រ យ៉ាងពីរោះ បោះសំឡេងល្បីគ្រប់ទិសទី ឮដល់ស្តេចរាមាជើងព្រៃក៏បានប្រទានងារជាម៉ឺនឯកថែមទៀត។

**៣.រឿងរាមកេរ្តិ៍៖** អ្នកនិពន្ធ បានបកស្រាយឲ្យឃើញពីសកម្មភាពរបស់ព្រះរាម ដែលបានព្យាយាមធ្វើការដោះស្រាយទំនាស់វិបត្តិដែលបានកើតឡើង រវាងពាក្យសត្យ និងប្រពៃណីព្រះមហាក្សត្រ។ជាដំណោះស្រាយព្រះរាមបានចាកចេញពីព្រះនគរធ្វើដំណើរចូលទៅក្នុងព្រៃ

បួសជាឥសីរយៈពេល ១៩ឆ្នាំ ដើម្បីកុំឲ្យរាជវង្សមានទំនាស់ទាស់ទែងគ្នា និងដើម្បីកុំឲ្យបណ្តារាស្ត្រទទួលសេចក្តីទុក្ខសោក ដោយសារតែខ្លួនជាអ្នកដឹកនាំមិនល្អ។ •សិស្សអាចលើករឿងអ្វីមកបញ្ជាក់ក៏បានឱ្យតែមានលក្ខណៈត្រឹមត្រូវសមស្រប។ចាប់ពីបី រឿងឡើងទៅត្រឹមត្រូវគឺត្រូវបានពិន្ទុពេញ។

• រឿងដែលអាចលើកយកមកបញ្ជាក់មានច្រើនដូចជា៖

រឿងចចក រឿងកុមារកំព្រា រឿងភូមិតិរច្ឆាន រឿងគូលីកំណែន រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ រឿងព្រះវេស្សន្តរ រឿងតេជោយ៉ត...។

- **សរុបមតិ៖**

សរុបសេចក្តីមកស្របទៅតាមការបកស្រាយនិងឧទាហរណ៍ដែលបានបញ្ជាក់យ៉ាងច្បាស់ខាងលើយើងអាចដឹងបានថាសេចក្តីព្យាយាមគង់បានសម្រេចពិតប្រាកដមែន។

**៣.សេចក្តីបញ្ចប់៖**

- **វាយតំលៃប្រធាន៖** ឆ្លងតាមការអធិប្បាយបកស្រាយបំភ្លឺលើខាងលើបានយើងអាចសន្និដ្ឋានបានថា ពំនោលរបស់បុព្វបុរសខាងលើពិតជាមានតម្លៃនិងអត្ថន័យដ៏ល្អជ្រាលជ្រៅបំផុត ហើយថែមទាំងបានផ្តល់ជាគតិអប់រំដោយយើងជាកូនចៅជំនាន់ក្រោយឲ្យខិតខំតស៊ូព្យាយាមពុះពារគ្រប់ឧបសគ្គទាំងអស់នោះយើងនឹងទទួលបាននូវសេចក្តីសម្រេចទៅតាមបំណងប្រាថ្នារបស់យើងជាពុំខាន។
- **មតិផ្ទាល់ខ្លួន៖** ដូច្នេះក្នុងនាមយើងជាកូនចៅជំនាន់ក្រោយ ក្រោយពីបានទទួលនូវបទអប់រំល្អពីបុព្វបុរសយើងនោះ យើងនឹងទទួលបាននូវជោគជ័យជម្នះជាពុំខាន។

❖ **រចនាបថ៖** ការប្រើប្រាស់អក្ខរាវិរុទ្ធនិងវេយ្យាករណ៍បានត្រឹមត្រូវ ទម្រង់តែងមានរបៀបរៀបរយល្អ ហើយអក្សរស្អាត។

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង ១៩ សីហា ២០១៩

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ (ថ្នាក់វិទ្យាសាស្ត្រ)

## រយៈពេល៖ ៩0នាទី ពិន្ទុ ៧៥

ប្រធាន៖ អក្សរសិល្ប៍ឆ្លុះបញ្ចាំងពីការប្រយុទ្ធរវាងភាវៈល្អនិងភាវៈអាក្រក់។

ចូរអ្នកបកស្រាយដោយយកអត្ថបទអក្សរសិល្ប៍មកបញ្ជាក់

## គម្រោងអត្ថាធិប្បាយ

### ១.សេចក្តីផ្តើម

- **លំនាំបញ្ហា៖** និយាយទាក់ទងទៅនឹងអក្សរសិល្ប៍
- **ចំណូលបញ្ហា៖** បញ្ចូលគំនិតប្រធាន
- **ចំណោទបញ្ហា៖** ចោទសួរតាមបែបប្រធានពន្យល់។

### ២.តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី៖**
- **ពន្យល់ពាក្យគន្លឹះ៖**
  - អក្សរសិល្ប៍៖ កម្រងអត្ថបទលើកយកពីបញ្ហាមនុស្សមកចោទនិងដោះស្រាយទៅតាមសីល្ប៍វិធីរបស់អ្នកនិពន្ធ
  - ប្រយុទ្ធ៖ តតាំង ប្រឆាំង ជម្លោះ ចម្បាំង...។
  - ភាវៈល្អ៖ ទង្វើឬសកម្មភាពដែលទ្រទ្រង់ភាពល្អប្រសើរ
  - ភាវៈអាក្រក់៖ ទង្វើឬសកម្មភាពដែលទ្រទង់ភាពអាក្រក់
- **ពន្យល់ន័យប្រធាន៖** ប្រធានខាងលើចង់បង្ហាញគ្រប់កម្រងអត្ថបទអក្សរសិល្ប៍សុទ្ធតែបានលើកយកបញ្ហាមនុស្សមកចោទនិងដោះស្រាយពោលគឺបានបង្ហាញឲ្យឃើញពីការប្រយុទ្ធប្រឆាំង តតាំងគ្នា ឬទំនាស់រវាងក្រុមមនុស្ស២ប្រភេទគឺ ពួកអ្នកធ្វើសកម្មភាពល្អនិងអ្នកធ្វើសកម្មភាពអាក្រក់។

- **បំណាកស្រាយប្រធាន៖**
  - គំនិតទូទៅនៃអក្សរសិល្ប៍...
  - មូលហេតុនៃជម្លោះបណ្តាលមកពី៖

-ការពង្រីកអំណាច

-ទស្សនៈគំនិតផ្ទុយគ្នា

-ការប៉ះពាល់ផលប្រយោជន៍គ្នាទៅវិញទៅមក

-លាភសក្ការៈ

-ស្នេហា

-ច្រណែនឈ្នានីស

-សង្គ្រាមឈ្លានពាន

-ផលប្រយោជន៍បុគ្គល

-អំពើអយុត្តិធម៌សង្គម

-ជំនឿ ទំនៀមទម្លាប់ ប្រពៃណី ផ្នត់គំនិត ទស្សនៈតឹងតែងខ្លាំងពេក

**ឧទាហរណ៍ ៖** តួអង្គមិនល្អម្តាយទាវ អរជូនក្រុមទាំង២នេះមានទំនាស់គ្នាដោយសារការប្រកាន់ប្រពៃណី អំណាចស្តេចត្រាញ់ផ្នត់គំនិតទស្សនៈមិនត្រូវគ្នា។ ទុំទាវចង់បានការជ្រើសរើសស្នេហាដោយខ្លួនឯង ឯចំណែកម្តាយនាងទាវចង់អនុវត្តទស្សនៈនំមិនធំជាងនាឡិ។ឯចំណែកអរជូនប្រើអំណាចរំលោភបំពានលើសិទ្ធិរបស់ទុំនិងទាវ

**-រឿងរាមកេរ្តិ៍៖** ភាវៈល្អ គឺព្រះរាមមានទំនាស់ជាមួយក្រុងរាពណ៍ ជាភាវៈអាក្រក់ ដោយសារក្រុងរាពណ៍បានឆក់យកនាងសីតាជាភរិយារបស់ព្រះរាម

+នាងសូបនខា មានទំនាស់ជាមួយព្រះរាមដោយសារស្នេហាខុសប្រពៃណី ទំនាស់កើតមានឡើងទៅជាមារសង្គ្រាមមួយយ៉ាងធំ

-**រឿងកុលាបប៉ៃលិន៖** ភាវៈល្អលោកហ្លួងរតនៈសម្បត្តិ ចៅចិត្រ យុននារី ភាវៈអាក្រក់ លោកបាឡាត់ស្រុក ចោរ មានទំនាស់គ្នាដោយសារពួកភាវៈអាក្រក់ មកបំពារបំពាន ប្រព្រឹត្តអំពើចោរកម្មលើលោកហ្លួងរតនសម្បត្តិ ចៅចិត្រជាមនុស្សល្អ

**៥.សរុបមតិ៖**

សរុបសេចក្តីមកឃើញថា គ្រប់អក្សរសិល្ប៍ទាំងអស់ដែលបានបកស្រាយបង្ហាញខាងលើសុទ្ធតែបញ្ជាក់ឲ្យឃើញថាទំនាស់តតាំងរវាងទង្វើឬសកម្មភាពល្អនិងទង្វើឬសកម្មភាពអាក្រក់ដោយសារអំណាច ស្នេហាច្រណែនឈ្នានីសផលប្រយោជន៍មិនយោគយល់អធ្យាស្រ័យឲ្យគ្នានឹងគ្នា។

**៣.បញ្ចប់សេចក្តី៖**

- **វាយតម្លៃប្រធាន៖** ឆ្លងតាមការបកស្រាយប្រធានខាងលើពិតជាមានអត្ថន័យ ខ្លឹម់សារដ៏ជ្រាលជ្រៅដោយអក្សរសិល្ប៍បានលើកយកបញ្ហាមនុស្សល្អនិងមនុស្សអាក្រក់មកបង្ហាញជាទំនាស់ទាស់ទែងនឹងគ្នាឲ្យអ្នកអានចេះបែងចែកអ្វីដែលល្អនិងអ្វីដែលអាក្រក់ដើម្បីទុកជាបទពិសោធន៍ឬជាគំរូដល់ក្មេងៗជំនាន់ក្រោយយកតម្រាប់តាម។ ជាពិសេសឲ្យស្គាល់ពីជំពូកមនុស្សនៅក្នុងសង្គមឲ្យបានច្បាស់លាស់មុននឹងសេពគប់ឬធ្វើការទំនាក់ទំនងគ្នា។
- **មតិផ្ទាល់ខ្លួន៖** ដូច្នេះ ក្នុងនាមយើងជាសិស្សត្រូវខិតខំសិក្សាគ្រប់ស្នាដៃអក្សរសិល្ប៍ដើម្បីឲ្យមានគំនិតទូលំទូលាយទៅលើស្ថានភាពសង្គមនិងស្រង់យកបទពិសោធន៍សម្រាប់ការរស់នៅប្រចាំថ្ងៃនិងរួមចំណែកអភិវឌ្ឍន៍សង្គម ។

❖ **រចនាបថ៖** អក្សរល្អ ឃ្លាប្រយោគល្អ ប្រើប្រាស់ប្លង់បានត្រឹមត្រូវ ខ្លឹមសារល្អ និងអក្ខរាវិរុទ្ធត្រឹមត្រូវ។

## ២.២. វិញ្ញាសាថ្នាក់សង្គម(២០១៤-២០១៩)

**ប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**
**សម័យប្រឡង៖ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤(លើកទី១)**
**វិញ្ញាសា៖ អក្សរសាស្ត្រ(ថ្នាក់វិទ្យាសាស្ត្រសង្គម)**
**រយៈពេល៖ ១៥០នាទី**

### ប្រធាន

ពាក្យចាស់លោកពោលថា៖ «តែខំច្រើនកើនចំណេះ តែចេះការច្រើនជាច្ច័យ តែខំរៀនសូត្រ រាល់ខែថ្ងៃ ដូចឆ្នៃត្បូងពេជ្រលេចពន្លឺ»។ ចូរបកស្រាយដោយរកអំណោះអំណាងក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់។

### <u>គម្រោងតែង</u>

**១.សេចក្តីផ្តើម**

- លំនាំបញ្ហា៖ និយាយទាក់ទងនឹងប្រធាន។
- ចំណូលបញ្ហា៖ បញ្ចូលប្រធាន។
- ចំណោទបញ្ហា៖ តើពំនោលខាងលើ មានអត្ថន័យដូចម្តេច?

**២.តួសេចក្តី**

- ឃ្លាភ្ជាប់សេចក្តី៖ ជាបឋម.........ជាមុនសិន។
- ពន្យល់ពាក្យ៖
    - \+ កើនចំណេះ៖ គឺការរីកចម្រើននូវចំណេះ ជំនាញ ការចេះដឹងគ្រប់សព្វសារពើ។
    - \+ បច្ច័យ៖ គឺជាហេតុ ជាដើមចម។
    - \+ ច្នៃ៖ គឺកែលម្អ ឬធ្វើអ្វីមួយដែលគ្មានសោភ័ណ គ្មានតម្លៃ គ្មានប្រយោជន៍ ឱ្យទៅជាមានប្រយោជន៍ មានតម្លៃ។

- ពន្យល់ន័យប្រធានៈ ប្រធានខាងលើមានន័យថា តែខំច្រើននាំឱ្យមានការរីកចម្រើននូវការចេះដឹង ចំណេះ និងជំនាញសព្វសារពើ បើចេះការងារច្រើនគឺជាហេតុដើមចម ហើយបើខំរៀនសូត្ររាល់ខែថ្ងៃប្រៀបដូចជាការកែលម្អត្បូងពេជ្រឱ្យលេចចេញជាពន្លឺ។
- បកស្រាយប្រធានៈ ដោយឆ្លងកាត់បទពិសោធក្នុងជីវភាពរស់នៅ ក្នុងការងារ ក្នុងធម្មជាតិ ទើបចាស់បុរាណបានខិតខំចងក្រងជាក្បួនច្បាប់ផ្សេងៗ ដើម្បីជាគតិអប់រំ ប្រៀនប្រដៅដល់ជនានុជនជំនាន់ក្រោយឱ្យមានការយល់ដឹងពីវិធីនៃការបង្កើនចំណេះទូទៅពីហេតុផលផ្សេងៗ និងពីតម្លៃនៃការសិក្សារៀនសូត្រ។

  ក."តែខំច្រើនកើនចំណេះ" មានន័យថា កាលណាបុគ្គលគ្រប់រូបខិតខំប្រឹងប្រែងពុះពារជម្នះនូវឧបសគ្គនានា តែងតែទទួលបាននូវចំណេះ និងបទពិសោធន៍ច្រើន...។

  + ឧទាហរណ៍ រឿងកុលាបប៉ៃលិនៈ ចៅចិត្រខិតខំបំពេញការងារជាកម្មករត្បូង នាំឱ្យគាត់ស្ទាត់ជំនាញលើកិច្ចការជីកត្បូង រហូតក្លាយជាអ្នកគ្រប់គ្រងអណ្តូងរ៉ែ...។
  + រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ៈ ការព្យាយាមរបស់សមក្នុងមុខរបរកសិកម្ម នាំឱ្យសមក្លាយជាកសិករគំរូរហូតអ្នកស្រុកបោះឆ្នោតឱ្យសមធ្វើជាគណ:កម្មការឃុំ...។
  + រឿងមាយើងៈ ដោយសេចក្តីព្យាយាមអនុវត្តតាមការណែនាំរបស់ប្រពន្ធ ទើបនាំឱ្យចៅមាណពបានក្លាយជាមន្ត្រីជំនិតរបស់ព្រះរាជា...។
  + រឿងកុមារកំព្រាៈ ការព្យាយាមរបស់កុមារប្អូនក្នុងការធ្វើជុចដាក់ត្រី នាំឱ្យជំនាញធ្វើជុចរបស់កុមារមានការវិវឌ្ឍ ពីជុចដាក់ត្រី ទៅជុចដាក់ម្រឹម រហូតដល់ជាប់យក្ស...។
  + អាចលើកឧទាហរណ៍រឿងផ្សេងៗក៏បានឱ្យតែពាក់ព័ន្ធ...។

ខ."តែចេះការច្រើនជាបច្ច័យ" មានន័យថា កាលណាបុគ្គលយល់ដឹងពីរបៀបនៃការធ្វើការងារច្រើន នឹងនាំឱ្យបុគ្គលក្លាយជាអ្នកមានហេតុផលល្អ មានការយល់ដឹងពីតម្លៃនៃការងារ មិនប្រមាទការងារ ចេះទាញយកប្រយោជន៍ពីការងារ...។

  + រឿងកុលាបប៉ៃលិន : ដោយសារតែមានការយល់ដឹងពីការងារច្រើន(ជីកត្បូង បើកឡាន និងការងារប្រចាំថ្ងៃ) ទើបធ្វើឱ្យចៅចិត្រ មានការចាប់អារម្មណ៍ពីលោកហ្លួងរតនសម្បត្តិ និងនាងឃុននារី...។
  + រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ : សមមានការយល់ដឹងពីជីវិតជាកម្មករ និងជាកសិករ ទើបគាត់ហ៊ានឆ្លើយបដិសេធលុយ៥០០រៀលរបស់លោករដ្ឋម

ន្ត្រីក្មេង និងត្រូវបានអ្នកស្រុក បោះឆ្នោតជ្រើសរើសតាំងជាគណៈកម្មការឃុំក្នុងសង្គមរាស្ត្រនិយម...។

+ រឿងតេជោយ៉ត៖ ដោយសារមានការយល់ដឹងច្រើនពីក្បួនតម្រាពិជ័យសង្គ្រាម ទើបតេជោយ៉តអាចដឹកនាំទ័ពបង្ក្រាបឈ្លើយសឹកសៀមបានជោគជ័យ ពិសេសអាចធ្វើឱ្យយ៉តអាចរកសត្រូវពីក្រោយខ្នងបានទៀតផង...។

ខ."តែខំរៀនសូត្ររាល់ខែថ្ងៃ ដូចឆ្នៃត្បូងពេជ្រលេចពន្លឺ" មានន័យថា បើកាលណាបុគ្គលគ្រប់រូប ខិតខំព្យាយាមរៀនសូត្រជាប្រចាំនោះបុគ្គលនោះនឹងមានចំណេះដឹងជ្រៅជ្រះ មានកេរ្តិ៍ឈ្មោះល្បីសុសសាយដូចជាត្បូងពេជ្រ។ ត្បូងពេជ្រកាលដើមឡើយ គ្រាន់តែជាដុំគ្រួស ជារ៉ែធម្មជាតិ លុះក្រោយពេលធ្វើការកែឆ្នៃរួចមក វាក៏ក្លាយជាត្បូងដែលមានពន្លឺ មានសោភ័ណ មានតម្លៃ គួរជាទីពេញនិយមនៃអ្នកដទៃ។

+ រឿងរាមកេរ្តិ៍៖ ព្រះរាមមានកេរ្តិ៍ឈ្មោះល្បីល្បាញ ក៏ព្រោះតែព្រះអង្គ ជាអ្នកមានថ្វីដៃក្នុងការប្រកួតប្រជែងលើកធ្នូកៅទណ្ឌសហស្សថាម និងបង្ក្រាបសត្រូវនានា។ ទ្រង់ទទួលបានចំណេះដឹងនេះ ដោយសារទ្រង់បានសិក្សាចប់គម្ពីរវេទជាមួយឥសីស្វាមិត្រ។

+ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖ សម្ដេចនរោត្ដមសីហនុ បិតាឯករាជ្យជាតិ ព្រះអង្គមានការសិក្សាខ្ពស់ទាំងវិទ្យាសាស្ត្រសង្គម បច្ចេកទេស ការគ្រប់គ្រង បានធ្វើឱ្យព្រះកិត្តិនាមព្រះអង្គល្បីល្បាញពេញពិភពលោក...។

- សរុបមតិ៖ រួមសេចក្ដីមក ដោយមានហេតុផលដូចដែលបានបកស្រាយខាងលើ យើងឃើញថា បើបុគ្គលខំច្រើននាំឱ្យរីកចម្រើនផ្នែកចំណេះ តែចេះការងារច្រើនជាលំនាំនាំឱ្យស្គាល់ហេតុផល ហើយបើខិតខំរៀនសូត្រជាប្រចាំនាំឱ្យមានភាពល្បីល្បាញ។

## ៣.បញ្ចប់សេចក្ដី

- វាយតម្លៃប្រធាន៖ ពំនោលពិតជាមានអត្ថន័យល្អក្នុងការអប់រំមនុស្សទូទៅឱ្យស្គាល់ពីតម្លៃនៃការខិតខំព្យាយាមរៀនសូត្រ និងបំពេញការងារផ្សេងៗ ដើម្បីប្រយោជន៍ និងកេរ្តិ៍ឈ្មោះ...។
- មតិផ្ទាល់ខ្លួន៖ ដូច្នេះ បុគ្គលទាំងឡាយគួរតែខិតខំព្យាយាមសិក្សា

**ប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**
**សម័យប្រឡងៈ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥**
**វិញ្ញាសាៈ អក្សរសាស្ត្រ( ថ្នាក់វិទ្យាសាស្ត្រសង្គម )**
**រយៈពេលៈ ១៥០នាទី**

## <u>ប្រធាន</u>

ទស្សនៈមួយចែងថា «ការតស៊ូគឺជាគន្លឹះ ដើម្បីទទួលបានសុភមង្គល»។ ចូរបកស្រាយទស្សនៈនេះ ដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់។

## <u>គម្រោងតែង</u>

### ១.សេចក្តីផ្តើម

- លំនាំបញ្ហាៈ និយាយឱ្យទាក់ទងទៅនឹងប្រធាន។
- ចំណូលបញ្ហាៈ លើកប្រធានយកមកបញ្ចូល"............."។
- ចំណោទបញ្ហាៈ ចោទសួរបែបពន្យល់។

### ២.តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តីៈ ដើម្បី.........ជាមុនសិន។
- ពន្យល់ពាក្យៈ
  + ការតស៊ូៈ ការប្រឹងប្រែងពុះពារជម្នះគ្រប់ឧបសគ្គ ការរើបម្រះ ការប្រយុទ្ធប្រឆាំង។
  + គន្លឹះៈ ផ្លូវ មធ្យោបាយ វិធី។
  + សុភមង្គលៈ សេចក្តីសុខកាយ សប្បាយចិត្ត សម្រេចផលដ៏ប្រសើរ។
- ពន្យល់ន័យប្រធានៈ ដូច្នេះ ប្រធានមានន័យថា ការប្រឹងប្រែងពុះពារជម្នះគ្រប់ឧបសគ្គ ការរើបម្រះ ការប្រយុទ្ធប្រឆាំង ជាមធ្យោបាយមួយនាំមកសេចក្តីសុខកាយ សប្បាយចិត្ត ឬសម្រេចផលដ៏ប្រសើរ។
- បកស្រាយប្រធានៈ

  ក.មានជីវិត មានឧបសគ្គ។ ដើម្បីជម្នះឧបសគ្គទាំងនោះ គេត្រូវតែធ្វើការតស៊ូប្រយុទ្ធប្រឆាំង ៖
  + សិស្សខិតខំរៀនសូត្រ នាំឱ្យសម្រេចបំណង
  + ប្រឹងប្រែងក្នុងការងារទទួលបានលទ្ធផលល្អ
  + ប្រឹងប្រែងជម្នះលើធម្មជាតិ ជួយសម្រួលដល់ការរស់នៅ

+ ការតស៊ូប្រយុទ្ធប្រឆាំងនឹងការជិះជាន់ក្មេងប្រវ័ញ្ច ទទួលបាននូវសេរីភាព ឯករាជ្យ ចាកផុតពីទុក្ខលំបាក...
+ ការតស៊ូក្នុងជីវភាពរស់នៅ ទើបចាកផុតពីភាពក្រីក្រ...។

ខ.ឧទាហរណ៍ក្នុងអក្សរសិល្ប៍ខ្មែរ ៖

- ❖ រឿងកុលាបប៉ៃលិន : ចៅចិត្រខិតខំរៀនសូត្រ ទទួលបានប្រកាសនីយបត្រ មានសមត្ថភាព ចេះថែទាំសុខភាព ចៀសផុតពីជំងឺគ្រុនចាញ់ សមត្ថភាពគ្រប់គ្រងបញ្ជីត្បូង...ប្រឆាំងចោរប្លន់...។ ចៅចិត្របានតស៊ូគ្រប់ឧបសគ្គក្នុងជីវិត រហូតដល់ចៅចិត្របានក្លាយខ្លួនពីកម្មករតូចទាបទៅជាចៅកែវ៉ៃយក្មេងនៅប៉ៃលិន...។
- ❖ រឿងភូមិតិរច្ឆាន : តួអង្គជូន នៅ ក្រុមបាតុករ នាងនីនាងប៊ី បានតស៊ូដោយកម្លាំងកាយ និងមតិ រហូតទទួលបានសេរីភាព ដោយបារាំងបានបន្ធូរបន្ថយលើបញ្ហាជិះជាន់ គាបសង្កត់។
- ❖ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ : សម បានតស៊ូក្នុងជីវិតក្រលំបាកតោកយ៉ាក។ ទីបំផុតបានក្លាយជាកសិករថ្មីមានជីវភាពល្អប្រសើរឡើងវិញ។
- ❖ រឿងព្រះវេស្សន្តរ : តួអង្គព្រះវេស្សន្តរបានតស៊ូប្រឹងប្រែងជម្នះគ្រប់ឧបសគ្គក្នុងការបំពេញទានបារមី ដើម្បីសម្រេចក្នុងការត្រាស់ដឹង ដើម្បីសេចក្ដីសុខសត្វលោកទាំងមូល។
- ❖ រឿងតេជោយ៉ត : យ៉តប្រឆាំងសត្រូវឈ្លានពាន យកជ័យជម្នះជូនជាតិមាតុភូមិ ជាពិសេសការប្រឆាំងទៅនឹងការរើសអើងវណ្ណៈជាតិសាសន៍ក្នុងសង្គម...។

❖ **កំណត់សម្គាល់** : អាចលើករឿងផ្សេងក្នុងអក្សរសិល្ប៍ខ្មែរដែលទាក់ទងនឹងប្រធាននេះ។

- សរុបមតិ៖ ជារួមមក យើងអាចសរុបសេចក្ដីបានថា ការតស៊ូប្រឹងប្រែងអំណត់ព្យាយាម រមែងតែងទទួលបាននូវសុភមង្គលយ៉ាងពិតប្រាកដ។

២.បញ្ចប់សេចក្ដី

- វាយតម្លៃ៖ ប្រធានមានអត្ថន័យល្អ ក្នុងការអប់រំមនុស្សឱ្យចេះតស៊ូប្រឹងប្រែងក្នុងជីវិត ...។

មតិផ្ទាល់ខ្លួន៖ ដូចនេះ...............។

**ប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**
**សម័យប្រឡង៖ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦**
**វិញ្ញាសា៖ អក្សរសាស្ត្រ(ថ្នាក់វិទ្យាសាស្ត្រសង្គម)**
**រយពេល៖ ១៥០នាទី**

## ប្រធាន

ទស្សនៈមួយចែងថា «ការអប់រំគឺជាសិទ្ធិសេរីភាពដែលបើកផ្លូវឱ្យមនុស្សសម្រេចបានភាពថ្លៃថ្នូរក្នុងជីវិត»។ ចូរបកស្រាយទស្សនៈនេះ ដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់។

## គម្រោងតែង

### ១.សេចក្តីផ្តើម

- លំនាំបញ្ហា៖ និយាយបញ្ហាទូទៅទាក់ទងទៅនឹងប្រធាន។
- ចំណូលបញ្ហា៖ បញ្ចូលប្រធាន។
- ចំណោទបញ្ហា៖ ចោទសួរតាមបែបប្រធានពន្យល់។

### ២.តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ដើម្បី.........ជាមុនសិន។
- ពន្យល់ពាក្យ៖
    - ❖ ការអប់រំ៖ សំដៅលើការណែនាំទូន្មានប្រៀនប្រដៅក្រើនរំឭកឱ្យល្អប្រពៃ ដើម្បីកែប្រែបុគ្គលិកលក្ខណៈរបស់មនុស្ស។
    - ❖ សិទ្ធិសេរីភាព៖ អំណាចបុគ្គលដែលអាចធ្វើអ្វីៗបានស្របតាមផ្លូវច្បាប់។
    - ❖ ភាពថ្លៃថ្នូរ ៖ ភាពល្អប្រសើរថ្លៃថ្លា ឧត្តុងឧត្តម។
- ពន្យល់ន័យប្រធាន ៖ ដូច្នេះទស្សនៈប្រធានមានន័យថា ការណែនាំទូន្មានប្រៀនប្រដៅដាស់តឿន ក្រើនរំឭកឱ្យបានល្អប្រពៃ ដើម្បីកែប្រែបុគ្គលិកលក្ខណៈរបស់មនុស្ស គឺជាអំណាចនៃបុគ្គលម្នាក់ៗដែលអាចធ្វើអ្វីៗបានស្របតាមផ្លូវច្បាប់ ដើម្បីឱ្យមានភាពល្អប្រសើរថ្លៃថ្លា និង ឧត្តុង្គឧត្តមនៅក្នុង
  ជីវិត។
- បកស្រាយប្រធាន ៖ មនុស្សម្នាក់ៗអាចធ្វើឱ្យជីវិតរបស់ខ្លួនទទួលបានភាពថ្លៃថ្នូរ ដោយសារតែបុគ្គលមានសិទ្ធិទទួលបានការអប់រំជាមាគ៌ាដូចជាការអប់រំលើផ្នែកសីល

ធម៌ គុណធម៌ សុជីវធម៌ និងចំណេះជំនាញផ្សេងៗ ព្រមទាំងអប់រំឱ្យស្រឡាញ់ជាតិមាតុភូមិ វប្បធម៌ អរិយធម៌ បរិស្ថាន យុត្តិធម៌...។

ក.រូបភាពនៃការអប់រំ : ការអប់រំស្តែងឡើងតាមរយៈការអប់រំក្នុងគ្រួសារ ការអប់រំក្នុងសាលារៀន និងការអប់រំក្នុងសង្គម៖

- ការអប់រំក្នុងគ្រួសារ៖ គឺលោកឪពុក អ្នកម្តាយតែងតែណែនាំអប់រំកូនចៅឱ្យមានសីលធម៌ មានគុណធម៌ សុជីវធម៌។ ក្នុងគ្រួសារមួយ បើកូនចេះស្តាប់ដំបូន្មានឪពុកម្តាយ កូននោះនឹងទទួលបានភាពជោគជ័យ។
- ការអប់រំក្នុងសាលារៀន ៖ លោកគ្រូ អ្នកគ្រូជាឪពុកម្តាយទីពីរ តែងតែអប់រំសិស្សានុសិស្សឱ្យ មានចំណេះជំនាញ មានសីលធម៌ គុណធម៌ សុជីវធម៌ល្អ ចេះស្រលាញ់ទឹកដី វប្បធម៌ ទំនៀមទម្លាប់...។
- ការអប់រំក្នុងសង្គម៖ សង្គមអប់រំឱ្យមនុស្សមានបទពិសោធន៍ ស្រលាញ់សន្តិភាព យុត្តិធម៌ ភាពថ្លៃថ្នូរ និងចេះស្រាយបញ្ហាក្នុងជីវិត។

ខ.ឧទាហរណ៍នៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ ៖

- ការអប់រំក្នុងគ្រួសារ
  - រឿងកុមារកំព្រា៖ តួអង្គកុមារប្អូនយកគំរូ និងធ្វើតាមបណ្តាំឪពុកក្នុងការធ្វើជុចតាំងពីដាក់ត្រី ដាក់ដំរី និងចុងក្រោយក្លាយជាស្តេច។
  - រឿងកុលាបប៉ៃលិន ៖ តួអង្គចៅចិត្រស្តាប់តាមឪពុក «ខ្លួនទីពឹងខ្លួន»។ ចុងក្រោយ ចៅចិត្របានក្លាយជាកូនប្រសាលោកហ្លួងរតនសម្បត្តិ។
- ការអប់រំក្នុងសាលា
  - រឿងរាមកេរ្តិ៍៖ តួអង្គព្រះរាមបានហាត់រៀនជាមួយឥសីពិស្វាមិត្រចេះចប់គម្ពីរត្រៃវេទ មានសមត្ថភាពលើកធ្នូរួច ឈ្នះទេវៈឋនទាំងបី ហើយទទួលបាននាងសីតាធ្វើជាមហេសី។
  - រឿងគូលីកំណែន៖ តួអង្គម៉ឺងរៀនចប់បានការងារធ្វើជាអ្នករាជការ បានចេញតស៊ូក្នុងចលនាខ្មែរឥស្សរៈ ដើម្បីទាមទារឯករាជ្យ...។
- ក្នុងសង្គម
  - រឿងធនញ្ជ័យ៖ តួអង្គធនញ្ជ័យដកស្រង់ចំណេះពីសង្គមទទួលបានចំណេះដឹង អាចដោះស្រាយប្រស្នាចិនរួច...។
  - រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖ សួន សមបានឆ្លងកាត់បទពិសោធន៍ការងារជាកម្មករផង ជាកសិករផង។ ចុងក្រោយបានក្លាយជាកសិករគំរូ និងជាគណៈកម្មការឃុំនៃសម័យសង្គមរាស្ត្រនិយម។

– សរុបមតិ៖ សរុបសេចក្តីមក.......................................។

## ៣.បញ្ចប់សេចក្តី

– វាយតម្លៃប្រធាន៖ ឆ្លងតាមការបកស្រាយខាងលើ ប្រធានមានខ្លឹមសារល្អក្នុងការអប់រំសិស្ស និស្សិត និងមនុស្សទូទៅឱ្យយល់ពីសិទ្ធិក្នុងការទទួលយកការអប់រំ សម្រាប់កែប្រែជីវិតរបស់ខ្លួន ដើម្បីរស់នៅក្នុងសង្គមមួយឱ្យមានភាពថ្លៃថ្នូរ។

– មតិផ្ទាល់ខ្លួន៖ ដូចនេះ............(ទស្សនៈផ្ទាល់ខ្លួន)។

**ប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**
**សម័យប្រឡង : ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧**
**វិញ្ញាសា: អក្សរសាស្ត្រ(ថ្នាក់វិទ្យាសាស្ត្រសង្គម)**
**រយៈពេល :១៥០នាទី**

## ប្រធាន

នៅក្នុងច្បាប់ល្បើកថ្មី អ្នកព្រះភិរម្យភាសាអ៊ូ ហៅ ង៉ុយ បានពោលថា “បម្រើមើលពុត ប្រាជ្ញាឱ្យមុត ស្មារតីឱ្យមាន បើខ្លៅឱ្យប្រាជ្ញ បើខ្លាចឱ្យហ៊ាន ចង់បានរបៀន កុំអៀនកុំខ្មាស់”។ ចូរអ្នកបកស្រាយដោយយកឧទាហរណ៍ក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់។

## គម្រោងតែង

### ១.សេចក្តីផ្តើម

- លំនាំបញ្ហា ៖ និយាយទាក់ទងទៅនឹងប្រធាន។
- ចំណូលបញ្ហា៖ លើកយកប្រធានមកសរសេរ។
- ចំណោទបញ្ហា៖ ចោទសួរលើប្រធានបទ(ចោទបែបពន្យល់)។

### ២.តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ ជាបឋម.........ជាមុនសិន។
- ពន្យល់ពាក្យ៖
    - ពុត៖ កិច្ចកលមាយា ល្បិចកិច្ចកល។
    - មុត៖ សំដៅលើភាពច្បាស់លាស់ ឈ្លាសវៃភ្លឺថ្លា។
    - ខ្លៅ៖ មិនចេះ មិនដឹង មិនយល់ ល្ងិតល្ងង់។
    - ប្រាជ្ញ៖ ឈ្លាសវៃ វៃឆ្លាត ប៉ិនប្រសប់។
    - របៀន៖ ចំណេះដែលចេះពីការរៀនសូត្រ។
- ពន្យល់ន័យប្រធាន៖ មានន័យថា មុននឹងជ្រើសរើសយកនរណាម្នាក់មកបម្រើការ ឬទៅបម្រើអ្នកដទៃ ត្រូវមានភាពឈ្លាសវៃ មានស្មារតីក្នុងការមើលមារយាទ ល្បិចកិច្ចកលនៃបុគ្គលនោះ ហើយប្រសិនបើចង់បានចំណេះទាល់តែឈ្លាសវៃ ក្លាហាន ហ៊ានសួរដោយមិនខ្មាស់អៀន។
- បកស្រាយប្រធាន៖ បណ្តាំលោកតាក្រមង៉ុយ ពិតជាបង្កប់ន័យល្អសម្រាប់ជាការទូន្មានកុលបុត្រ កុលធីតា ខ្មែរជំនាន់ក្រោយ ៖

ក. “បម្រើមើលពុត ប្រាជ្ញាឱ្យមុត ស្មារតីឱ្យមាន” មានន័យថានៅក្នុងជីវភាពរស់នៅមនុស្សយើងម្នាក់ៗតែងមានកិច្ចការច្រើនដែលត្រូវបំពេញតាមភារកិច្ចរៀងៗខ្លួន។ ជួនកាលកិច្ចការខ្លះអាចធ្វើបានដោយខ្លួនឯង ឯការងារទៀតត្រូវពឹងពាក់អ្នកដទៃឱ្យជួយ ឬមកបម្រើ មិនថាការងារផ្ទះ ឬជាការងារក្រុមហ៊ុនឡើយ។ ម្ចាស់ផ្ទះ ម្ចាស់ក្រុមហ៊ុន ឬថ្នាក់ដឹកនាំស្ថាប័នរាជការ គប្បីជ្រើសរើសយកអ្នកបម្រើ ឬបុគ្គលិកឱ្យមកជួយកិច្ចការរបស់ខ្លួន ដោយត្រូវចេះពិនិត្យឬកពា មារយាទអ្នកបម្រើ ឬបុគ្គលិកទាំងនោះជាមុន ដើម្បីគេចផុតពីក្ដីអន្តរាយផ្សេងៗ។ តែបើយើងមិនបានមើពុតល្បិចកលអ្នកបម្រើ ឬបុគ្គលិកនោះ អាចនឹងនាំមកនូវក្ដីអន្តរាយដល់ម្ចាស់ ឬថៅកែ។ ម្យ៉ាងវិញទៀត កំណាព្យខាងលើក៏ចង់បានន័យថា បើនរណាម្នាក់ទៅបម្រើការឱ្យគេ គប្បីមើលកិរិយាមារយាទពុតត្បុត ឬចំណង់ចំណូលចិត្តរបស់ថៅហ្វាយនាយជាមុនផង ទើបគេអាចទទួលបានការពេញចិត្ត ឬចៀសផុតពីការចាញ់បោក ឬទុក្ខទោសផ្សេងៗ...។

+ ឧទាហរណ៍ក្នុងអក្សរសិល្ប៍ប្រជាប្រិយ ៖

  - រឿងឪពុកក្មេករើសកូនប្រសា៖ បុរសទីមួយមិនបានពុតរបស់ឪពុកក្មេក ទើបបរាជ័យ។ ឯបុរសទីពីរ ដឹងពីពុត ឬកិរិយាមារយាទរបស់ឪពុកក្មេកក៏ទទួលបានជោគជ័យ។ រីឯតាជាឪពុកមិនចេះមើលពុតបុរសទីពីរ ក៏ទទួលបរាជ័យ...។
  - រឿងមាយើង៖ ថៅមាណពមិនបានយល់ពីពុត ឬ ឥរិយាបថរបស់ស្ដេច ទើបមាណពស្ទើរបាត់បង់ជីវិត...។
  - រឿងធនញ្ជ័យ៖ សេដ្ឋីមិនមើលពុតធនញ្ជ័យ ទើបធ្វើឱ្យខ្លួនវិនាស...។

+ ឧទាហរណ៍ក្នុងអក្សរសិល្ប៍ទំនើប៖

  - រឿងកុលាបប៉ៃលិន៖ លោកហ្លួងរតនសម្បត្តិយល់ពីឥរិយាបថមារយាទរបស់ថៅចិត្រ ទើបលោកប្រគល់ការងារឱ្យថៅចិត្រធ្វើ...។
  - រឿងថៅកែចិត្តចោរ...
  - រឿងតេជោយ៉ត...

ក.”បើខ្លៅឱ្យប្រាជ្ញ បើខ្លាចឱ្យហ៊ាន ចង់បានរបៀន កុំអៀនកំខ្មាស” មានន័យថា មនុស្សម្នាក់ៗនៅក្នុងសង្គមតែងតែភ្ជាប់នូវភាពល្ងិតល្ងង់ជាមួយខ្លួន ហើយពួកគេតែងតែចង់បាននូវចំណេះដឹងសព្វសារពើដើម្បីកែប្រែខ្លួនទៅជាអ្នកមានសមត្ថភាព អាចយល់បាននូវកិច្ចការទូទៅ និងបំពេញការងារផ្សេងៗបានជោគជ័យ។ ដើម្បីសម្រេចគោលដៅខាងលើនេះ

មនុស្សចាំបាច់ត្រូវស្វែងរកការសិក្សារៀនសូត្រប្រកបដោយភាពឈ្លាសវៃ រហ័សរហួន ហ៊ានសួរ ហ៊ានឆ្លើយ ចេះមើលអ្នកដទៃជាគំរូ...។

+ ឧទាហរណ៍ក្នុងអក្សរសិល្ប៍ប្រជាប្រិយ ៖
    - រឿងអ្នកក្រនៅក្បែរផ្ទះសេដ្ឋីធ្វើគ្រាប់សេដ្ឋី៖ អ្នកក្របានយកគំរូសេដ្ឋី រហូតក្លាយជាអ្នកមាន...។
+ ឧទាហរណ៍ក្នុងអក្សរសិល្ប៍បុរាណ ៖
    - រាមកេរ្តិ៍៖ ព្រះរាមបានទៅរៀនយុទ្ធសិល្ប៍ជាមួយឥសីពិស្វាមិត្រ ...ចេះចប់គម្ពីរត្រៃវេទ...។
    - រឿងទុំទាវ៖ ទុំបានរៀននៅវត្តវិហារធំ រហូតចេះស្មូត មើលសាស្ត្រា ធ្វើតោក...
    - រឿងផ្កាស្រពោន៖ ប៊ុនធឿន...
    - រឿងចៅកែចិត្តចោរ៖ ផានីត...។

– <u>សរុបមតិ៖</u> សរុបសេចក្តីមក អ្នកបម្រើគេ ឬរើសរកអ្នកបម្រើសំខាន់ត្រូវចេះមើលពុតអ្នកដែលយើងសេពគប់ ម្យ៉ាងទៀតប្រសិនបើចង់បានចំណេះ មនុស្សគប្បីត្រូវឈ្លាសវៃ ក្លាហាន សួរនាំ យកគំរូតាមអ្នកដទៃដែលជាអ្នកជោគជ័យ។

## ៣.បញ្ចប់សេចក្តី

– វាយតម្លៃប្រធាន៖ ប្រធានខាងលើពិតជាមានខ្លឹមសារអប់រំល្អសម្រាប់មនុស្សទូទៅ ឱ្យចេះមើលកិរិយាមារយាទ(ពុត)មនុស្ស មុននឹងសេពគប់ និងបង្ហាញពីវិធីក្នុងការស្វែងរករៀន ប្រកបដោយភាពក្លាហាន ឈ្លាសវៃ ដើម្បីទទួលបានភាពជោគជ័យនៅក្នុងជីវិត...។

– មតិផ្ទាល់ខ្លួន៖ ដូច្នេះ...(មតិរបស់សិស្ស)។

**ប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**
**សម័យប្រឡង : ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨**
**វិញ្ញាសា: អក្សរសាស្ត្រ(ថ្នាក់វិទ្យាសាស្ត្រសង្គម)**
**រយៈពេល :១៥០នាទី**

## ប្រធាន

ទស្សនៈមួយចែងថា "វិជ្ជាជាអលង្ការរបស់មនុស្សគ្រប់រូប"។ ចូរបកស្រាយទស្សនៈនេះ ដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់។

## គម្រោងតែង

### ១.សេចក្តីផ្តើម

- លំនាំបញ្ហា៖ និយាយទាក់ទងនឹងប្រធាន។
- ចំណូលបញ្ហា៖ លើកប្រធានមកបង្ហាញក្នុងអព្ភន្តរសញ្ញា។
- ចំណោទបញ្ហា៖ ចោទបែបពន្យល់។

### ២.តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី៖ មុននឹង.........ជាមុនសិន។
- ពន្យល់ពាក្យគន្លឹះ៖
    + វិជ្ជា៖ ចំណេះដឹង ចំណេះប្រាជ្ញា សេចក្តីដឹងច្បាស់ ការចេះដឹងទៅលើចំណេះជំនាញផ្សេងៗ។
    + អលង្ការ៖ ជាទ្រព្យសម្បត្តិដែលជាគ្រឿងលម្អមានមាសប្រាក់ កែវកង បើតាមន័យប្រធាននេះ អលង្ការសំដៅលើបុគ្គលិកលក្ខណៈល្អរបស់មនុស្ស។
- ពន្យល់ន័យប្រធាន៖ ដូច្នេះ ប្រធានមានន័យថា ចំណេះដឹងចំណេះប្រាជ្ញា ការចេះដឹង ឬចំណេះជំនាញផ្សេងៗគឺជាទ្រព្យសម្បត្តិរបស់មនុស្សគ្រប់រូប ឬជាបុគ្គលិកលក្ខណៈល្អរបស់មនុស្សគ្រប់រូប។
- បកស្រាយប្រធាន៖ ជាការពិតណាស់ វិជ្ជា ឬចំណេះដឹង ចំណេះប្រាជ្ញា ឬចំណេះជំនាញផ្សេងៗគឺជាទ្រព្យសម្បត្តិរបស់មនុស្សគ្រប់រូបទុកដូចជាគ្រឿងលម្អខ្លួនរបស់មនុស្សដែលមានតម្លៃ ព្រោះវិជ្ជាធ្វើឱ្យមនុស្សជួបសេចក្តីសុខ មានជីវភាពធូរធារ ថ្លៃថ្នូរ មានកិត្តិយស និងកេរ្តិ៍ឈ្មោះ។

  ក.គំនិតសំខាន់៖

+ វិជ្ជាជាទ្រព្យជាប់នឹងប្រាណ ចោរលួចមិនបាន
+ ចាយច្រើនចម្រើនឡើង
+ កណ្ដៀរមិនកោរ កណ្ដុរមិនកាត់
+ មនុស្សមានវិជ្ជាតែងមានសុជីវធម៌ សីលធម៌ សប្បុរសធម៌
+ មនុស្សមានវិជ្ជាមានតម្លៃ មានកិត្តិយស
+ មនុស្សមានវិជ្ជាមានជីវភាពធូរធារ
+ មានការងារ...។

ខ.អំណះអំណាងក្នុងស្នាដៃអក្សរសិល្ប៍៖

+ រឿងរាមកេរ្តិ៍៖ ព្រះរាមរៀនចប់គម្ពីរត្រៃវេទ អាចលើកធ្នូសររួច ឈ្នះសត្រូវគ្រប់ទិសទី...។
+ រឿងកុមារកំព្រា៖ តួអង្គកុមារប្អូន ដោយសារមានចំណេះធ្វើជុច ទើបទទួលបានលាភ សក្ការៈ និងមានកិត្តិយសជាស្ដេច...។
+ រឿងតេជោយ៉ត៖ តួអង្គយ៉ត ដោយសារតែមានវិជ្ជា ទើបទទួលងារជា"តេជោយ៉ត"ជាមេទ័ពដែនកំពង់ស្វាយ...។
+ រឿងប្រះអាទិត្រថ្មីរះលើផែនដីចាស់៖ លោករដ្ឋមន្ត្រីក្មេងបានទៅរៀននៅស្រុកបារាំង ទើបទទួលកិត្តិយសជារដ្ឋមន្ត្រី...។
+ រឿងទុំទាវ៖ តួអង្គទុំមានវិជជ្ជាខាងស្មូត ក្លាយជាម៉ឺនឯក...។
+ រឿងកុលាបប៉ៃលិន៖ ចៅចិត្រ ដោយសារមានវិជ្ជា ទើបចៅចិត្រទទួលការទុកចិត្តពីលោកហ្លួងរតនសម្បត្តិពេញរហូតប្រគល់នាងឃុននារីឱ្យជាភរិយា...។

– សរុបមតិ៖ សរុបសេចក្ដីមក វិជ្ជាជាគ្រឿងអលង្ការរបស់មនុស្សពិតប្រាកដមែន។

## ៣.សេចក្ដីបញ្ចប់

– វាយតម្លៃប្រធាន៖ ឆ្លងតាមការអធិប្បាយស្រាយបំភ្លឺខាងលើយើងអាចសន្និដ្ឋានបានថា មតិប្រធានពិតជាមានន័យល្អ បានអប់រំមនុស្សទូទៅឱ្យស្វះស្វែងស្វាធ្យាយរកនូវវិជ្ជាមកដាក់ក្នុងខ្លួន ហើយស្គាល់នូវតម្លៃនៃវិជ្ជា ដើម្បីជួយខ្លួនឯង គ្រួសារ និងសង្គម...។
– មតិផ្ទាល់ខ្លួន៖ ដូចនេះ ក្នុងនាមយើង...(ទស្សនៈរបស់ស្មេរ)។

# ជំពូក៣   វិញ្ញាសាត្រៀមប្រើប្រាស់ក្នុងក្លិប

## ៣.១. វិញ្ញាសាត្រៀមឆ្នាំ២០១៨

**ប្រធាន៖** មានទស្សនៈមួយលើកឡើងថា “រឿងចៅកែចិត្តចោរជាប្រភេទលក្ខណៈអក្សរសិល្ប៍តថនិយមរិះគន់”

តើការស្លាប់នេះមានលក្ខណៈដូចម្តេចដែរ? ចូរបង្ហាញពីភស្តុតាងរបស់បុគ្គលមួយចំនួនក្នុងសង្គម។

**អត្រាកំណែ**

**១.សេចក្តីផ្តើម**

- **លំនាំបញ្ហា៖** និយាយទាក់ទងនឹងប្រធាន
- **ចំណូលបញ្ហា៖** បញ្ចូលប្រធានបទ...
- **ចំណោទបញ្ហា៖** តើទស្សនៈដែលបានលើកឡើងខាងលើនេះមានន័យដូចម្តេច?

**២.តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី ៖**
- **ពន្យល់ពាក្យគន្លឹះ៖**
    - ពាក្យ “អក្សរសិល្ប៍តថនិយមរិះគន់” មានន័យថា ជាស្នាដៃអក្សរសិល្ប៍មួយបែបដែលបានបង្ហាញពីជីវិភាពពិតរបស់សង្គមព្រមទាំងបានវែកញែកឱ្យឃើញពីចំណុចល្អ និងអាក្រក់នៃសង្គមទៀតផង។
- **ពន្យល់ន័យប្រធាន ៖**

    ប្រធានបានបង្ហាញថា រឿងចៅកែចិត្តចោរគឺជាប្រភេទលក្ខណៈអក្សរសិល្ប៍ដែលនិយាយអំពីជីវភាពពិតជាក់ស្តែងក្នុងសង្គម ព្រមទាំងបានបង្កប់គំនិតរិះគន់វែកញែកឱ្យឃើញនូវលក្ខណៈជាវិជ្ជមាននិងអវិជ្ជមានដូចជា បាតុភាពអសកម្មទាំងឡាយដែលកើតមាននៅក្នុងសង្គមជាដើម។
- **បំណាកស្រាយ**

**ក.បំភ្លឺគំនិតទូទៅ**

ប្រវត្តិនៃសង្គមមនុស្សជាតិកន្លងមកតែងតែពោរពេញទៅដោយទំនាស់ស្មុគស្មាញបន្តគ្នាជាប់មិនដាច់និងប្រែប្រួលទៅតាមការវិវត្តនៃសង្គម។ ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ជាថ្ងៃប្រវត្តសាស្ត្រ ដែលប្រទេសជាតិត្រូវបានឯករាជ្យក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្ដេចនរោត្តមសីហានុ...។

**ខ.បំភ្លឺគំនិតប្រធាន**

- និយាយអំពីជីវិភាពរបស់ពួកកម្មករនិងតួអង្គពូហាំ។
- លើកយកពាក្យសម្ដីរបស់តួអង្គមកបញ្ជាក់ដើម្បីធ្វើជាតឹកតាងក្នុងការបកស្រាយទៅលើប្រធានបទ...។
- និយាយពីភាពអយុត្តិធម៌របស់ពូហាំដែលទទួលបានថៅកែចិត្តចោរ។
- និយាយអំពីបញ្ហាអសកម្មរបស់តួអង្គផានិត និងការបកអាក្រាតនូវអំពើយង់ឃ្នងរបស់ថៅកែ។

- **សរុបមតិ៖** និយាយស្របទៅតាមប្រធានបទ

**៣.សេចក្ដីបញ្ចប់**

- **វង្វាយតម្លៃ៖** ថ្លឹងថ្លែងទៅបំណាកស្រាយទៅតាមការយល់ឃើញ...។
- **មតិផ្ទាល់ខ្លួន ៖** លើកឡើងនូវការប្ដេជ្ញាចិត្ត...។

**ប្រធានបទ៖** មានមតិមួយពោលថា "វិស័យអប់រំ ជាសសរស្តម្ភនៃប្រទេសជាតិ"។

ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## គម្រោងតែង

### ១.សេចក្តីផ្តើម

- **លំនាំបញ្ហា ៖** ទន្ទឹមនឹងការអភិវឌ្ឍពីមួយថ្ងៃទៅមួយថ្ងៃ ប្រទេសនានាជាច្រើននៅក្នុងពិភពលោកបានខិតខំពង្រឹងខ្លួន បំប៉នសមត្ថភាពប្រជាពលរដ្ឋរបស់ឱ្យបានកាន់តែប្រសើរឡើងមិនថាចំណេះដឹង ចំណេះធ្វើ វិជ្ជាជីវៈ។ ដូចនេះដែរដើម្បីឱ្យប្រជាជនរបស់ពួកគេកាន់តែប្រសើរនូវរាល់ចំណុចទាំងនេះ បណ្តាប្រទេសនោះបានចាត់ទុកវិស័យអប់រំជាវិស័យចម្បងគេក្នុងការសាបព្រោះធនធានទាំងឡាយ។

- **ចំណូលបញ្ហា៖** ហេតុនេះហើយបានជាមានមតិមួយពោលថា "វិស័យអប់រំ ជាសសរស្តម្ភនៃប្រទេសជាតិ"។

- **ចំណោទបញ្ហា ៖** តើពំនោលខាងលើនេះមានន័យដូចម្តេចខ្លះ?

### ២.តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី ៖**

ដើម្បីជួយជំរុញឱ្យការបកស្រាយប្រធានឱ្យកាន់តែមានភាពងាយស្រួល និងពិស្តាឡើង យើងគប្បីស្វែងយល់នៃពាក្យគន្លឹះមួយចំនួនជាមុនសិន។

- **ពន្យល់ពាក្យគន្លឹះ៖**
  - វិស័យអប់៖ សម្តៅយកប្រព័ន្ធអប់រំ បណ្តុះបណ្តាលគ្រប់ជាន់ថ្នាក់រួមទាំងស្ថានប័នរដ្ឋ ឯកជន ទាំងផ្លូវការ (រៀនសូត្របន្តគ្នា)
  - សសរស្តម្ភ៖ គឺជាសសរដែលរឹងមាំ ជាសសរសំខាន់ដែលយើងអាចធៀបមកវិញថាជាមូលដ្ឋានគ្រឹះឬបង្គោលគ្រឹះសម្រាប់ទ្រទ្រង់អ្វីមួយឱ្យបានស្ថិតស្ថេរតទៅមុខ។

- **ពន្យល់ន័យប្រធាន ៖**

ដូច្នេះពំនោលខាងលើចង់និយាយថា បណ្តាប្រព័ន្ធអប់រំគ្រប់ជាន់ថ្នាក់រួមទាំងស្ថាប័នរដ្ឋឯកជនទាំងផ្លូវការ និងមិនផ្លូវការជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការការទ្រទ្រង់ប្រទេសជាតិឱ្យបានរឹងមាំ និងរីចម្រើនតទៅមុខជាដរាប។

**- បំណកស្រាយ ៖**

ជាការពិតណាស់វិស័យអប់រំពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឱ្យប្រទេសជាតិមានភាពរីកចម្រើនះ

- តាមរយៈការអប់រំធ្វើមនុស្សមានចំណេះដឹងខ្ពស់ អាចបញ្ចៀសប្រទេសជាតិពីការប្រមាថមើលងាយឬចង់បំពានពីសំណាក់ប្រទេសជិតខាង។ ឧ.តួអង្គធនញ្ជ័យក្នុងរឿងធនញ្ជ័យ
- បណ្តុះបណ្តាលប្រជាជនឱ្យមានមនសិកាជាតិ ទុករឿងសុខទុក្ខប្រទេសជាតិជាចម្បង ជាការសំខាន់បំផុតរឿងអ្វីៗទាំងអស់ ធ្វើឱ្យប្រជាជនយល់ភារកិច្ចចម្បងរបស់ពួកគេគឺជាតិ កិត្តិយសរបស់ពួកគេគឺជាកិត្តយសរបស់ជាតិ។ ឧ. តួអង្គទីឃាវុធក្នុងរឿងមាលាដួងចិត្ត
- បណ្តុះនូវស្មារតីសន្តិភាព ចេះដោះស្រាយវិបត្តិនានាក្នុងប្រទេសដោយគតិបណ្ឌិតដោយហេតុនិងផល និងការប្រកាន់សច្ចជាចម្បង។ ឧ. តួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍
- បណ្តុះនូវចរិយាមាទស្លូតត្រង់ ប្រកបដោយក្រមសីលធម៌ខ្ពស់ក្នុងការរស់នៅធ្វើឱ្យប្រជាជនយល់ថាមានតែសុតរិតភាពតែប៉ុណ្ណោះដែលធ្វើឱ្យពួកគេរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។ ឧ.តួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់
    - អប់រំឱ្យប្រជាជនមានទាំងចំណេះដឹងនិងចំណេះធ្វើ អាចឱ្យពួកគេរៀនរស់ដោយខ្លួនឯងពឹងខ្លួនឯង និងមានវិជ្ជាជីវៈគ្រប់គ្រាន់សម្រាប់បំពេញមុខងាររបស់ខ្លួន។ឧ.តួអង្គចៅចិត្រក្នុងរឿងកុលាបប៉ៃលិន

**- សរុបមតិះ**

សរុបមកឃើញថា វិស័យអប់រំពិតជាសសរស្តម្ភនៃប្រទេសជាតិ ជាហេតុនាំឱ្យប្រទេសជាតិកាន់តែរឹងមាំតាមរយៈធ្វើឱ្យមនុស្សនៅក្នុងសង្គមក្លាយជាធនធានមនុស្សដ៏ប្រសើរ មានក្រមសីលធម៌និងវិជ្ជាជីវៈត្រឹមត្រូវសម្រាប់ប្រកបកិច្ចការងាររបរចិញ្ចឹមជីវិត និងអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានសន្ទុះជាងមុនជាលំដាប់បន្តទៅទៀត។

**៣.សេចក្តីបញ្ចប់**

- **វាយតម្លៃប្រធាន៖**

ឆ្លងតាមការបកស្រាយខាងលើ ពំនោលខាងលើនេះពិតជាបានបង្កប់នូវអត្ថន័យយ៉ាងសម្បូរបែបសម្រាប់ឱ្យមនុស្សជាតិទូទៅយល់ថា ការអប់រំមានសារៈសំខាន់យ៉ាងខ្លាំងចំពោះប្រទេសជាតិទាំងមូល និងរួមចំណែកអ្វីខ្លះក្នុងការកសាងសង្គមជាតិពោរពេញដោយធនធានមនុស្សដ៏ប្រសើរ។ ជាហេតុធ្វើឱ្យពួកយើងត្រូវចិត្តទុកដាក់ឡើងវិញនូវវិស័យអប់រំរបស់ជាតិដើម្បីធានាបាននូវស្ថេរភាព សន្តិភាព និងអភិវឌ្ឍនភាពជានិច្ចនិរន្តរ៍។

- **មតិផ្ទាល់ខ្លួន ៖**

ដូច្នេះមនុស្សជំនាន់ក្រោយគ្រប់រូប គួរគប្បីឱ្យតម្លៃវិស័យអប់រំនេះជាចម្បង ដ្បិតថាមានតែប្រទេសដែលមានការអប់រំខ្ពស់ប៉ុណ្ណោះដែលអាចមានការរីកចម្រើន ខ្ពស់មុខខ្ពស់មាត់ មានកិត្តិយសក្នុងបណ្តាប្រទេសលើពិភពលោកបាន។ ជាពិសេសយើងក៏គួរតែបន្តលើកតម្កើងវិស័យអប់រំនេះបន្តទៀត ដើម្បីឱ្យប្រទេសយើងអាចបោះជំហានតាមទាន់បណ្តាប្រទេសក្នុងសង្គមអភិវឌ្ឍនានា។

**ប្រធាន៖** តួអង្គហាំក្នុងរឿងថៅកែចិត្តចោរបានពោលថា "សេចក្តីយុត្តិធម៌ទៀង បើយើងយកមកដាក់ក្នុងខ្លួនបានហើយ មិនចេះសាបសូន្យទេ"។

ចូរពន្យល់ដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍នានាមកបញ្ជាក់។

## អត្រាកំណែ

### ១.សេចក្តីផ្តើម

**- លំនាំបញ្ហា** ៖ ដើម្បីភាពជោគជ័យ ជ័យជម្នះ កិត្តិយស និងឧត្តមភាពក្នុងការរស់នៅប្រចាំថ្ងៃ មនុស្សបានប្រើប្រាស់វិធីសាស្ត្រផ្សេងៗមកសម្រេចរាល់បំណងប្រាថ្នាទាំងនោះ ខណៈអ្នកខ្លះដើរតាមផ្លូវសុចរិត រីឯអ្នកខ្លះទៀតដើរតាមផ្លូវទុច្ចរិត។ ដ្បិតផ្លូវទាំងពីរនាំឱ្យមនុស្សសម្រេចបាននូវក្តីបំណងរបស់ពួកគេក្តី ប៉ុន្តែអ្នកយកលំអានតាមតាមផ្លូវវៀចរមែងមានសេចក្តីភ័យខ្លាច មិនស្ងប់សុខនឹងអ្វីដែលខ្លួនទទួល ខណៈអ្នកតោងយកសេចក្តីទៀងត្រង់រមែងមានសេចក្តីសុខផ្លូវចិត្ត និងសន្តិភាពក្នុងផ្លូវអារម្មណ៍ជាប់ជាប្រចាំ។

**-ចំណូលបញ្ហា ៖** ដូច្នេះហើយបានជាតួអង្គហាំនៅក្នុងរឿងថៅកែចិត្តចោរពោលថា "សេចក្តីយុត្តិធម៌ទៀង បើយើងយកមកដាក់ក្នុងខ្លួនបានហើយ មិនចេះសាបសូន្យទេ"។

**- ចំណោទបញ្ហា ៖** តើពំនោលខាងលើនេះមានន័យដូចម្តេចខ្លះ?

### ២.តួសេចក្តី

#### ក.ឃ្លាភ្ជាប់សេចក្តី

ដើម្បីធ្វើការបកស្រាយប្រធានឱ្យបានក្បោះក្បាយនិងពេញលេញយើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះមួយចំនួននៅក្នុងប្រធានបទជាមុនសិន។

#### ខ.ពន្យល់ពាក្យគន្លឹះ

- យុត្តិធម៌ទៀង៖ សម្តៅទៅលើសេចក្តីទៀតត្រង់របស់មនុស្សដែលមានឱ្យគ្នាទៅវិញទៅមកដោយរក្សាបាននូវសុចរិតភាព ភក្តីភាព សច្ចភាពឥតលម្អៀង។
- មិនចេះសាបសូន្យ៖ មានន័យថាជាតម្លៃស្ថិតស្ថេរ គង់វង្ស យូរអង្វែង ជារៀងរហូត

#### គ.ពន្យល់ន័យប្រធាន

ដូច្នេះពំនោលខាងលើចង់និយាយថាសុចរិតភាព ភក្តីភាព និងសេចក្តីទៀងត្រង់របស់មនុស្ស បើសិនមនុស្សយកវាមកដាក់ក្នុងខ្លួនវាបានហើយ អំពើទាំងនោះនឹងគង់ស្ថិតក្នុងចិត្តនិងសតិអារម្មណ៍របស់គេជារៀងរហូត។

**ឃ. បំណកស្រាយ**

ជាការពិតណាស់មនុស្សណាម្នាក់ប្រកាន់បានតែសេចក្តីពិតឥតលម្អៀងជាប់មានជាដរាបតាំងពីក្មេងវ័យមក អំពើល្អៗទាំងនោះប្រាកដជាដក់ជាប់ក្នុងចិត្ត កាយ និងវិញ្ញារបស់គេពុំទៅណាឡើយ

- ដ្បិតថាប្រសិនជាគេមានបំណងចង់ព្រឹត្តអំពើអបាយណាមួយ នោះសតិសម្បជញ្ញៈរបស់គេនឹងដាស់តឿនគេភ្លាមថាប្រការនោះពុំគួរឡើយណានឹងប្រព្រឹត្តនោះឡើយ។ ឧ.តួអង្គសមក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់
- ធ្វើឱ្យគេក្លាយជាមនុស្សប្រកាន់ជាប់ភាពស្មោះត្រង់ជាដរាប មិនគេចកែ ឬហ៊ានប្រព្រឹត្តអំពើកេងបន្លំ ឬកិបកេងយកចំណេញពីភាពទុកចិត្តរបស់មនុស្សជុំវិញខ្លួន។ឧ.តួអង្គចៅចិត្រក្នុងរឿងកុលាបប៉ៃលិន
- មិនមានក្តីលោភៈ បំពានភក្តីភាពចំពោះមនុស្សដែលខ្លួនគោរព ព្រមទាំងដឹងរាល់អ្វីៗថាគួរធ្វើ ឬ មិនគួរធ្វើ មិនចេះតែធ្វើអំពើមិនគួរកប្បីតាមសេចក្តីត្រូវការរបស់ខ្លួនឯង។ឧ.តួអង្គភិរុតក្នុងរឿងរាមកេរ្តិ៍
- នឹងមានកិត្តយសនិងសេចក្តីថ្លៃថ្នូរក្នុងការរស់នៅក្នុងសង្គម ទទួលបានការគោរព អាណិត ស្រឡាញ់ពីគ្រប់មជ្ឈដ្ឋាន។ឧ.តួអង្គលឹមក្នុងរឿងគូលីកំនែន

**ង.សរុបមតិ**

សរុបមកឃើញថាបើមនុស្សប្រកាន់ខ្ជាប់តែអំពើល្អ ស្មោះស សុចរិត ទៀងត្រង់ហើយនោះ អំពើទាំងនឹងដក់ជាប់ក្នុងបេះដូង និងចិត្តគំនិតគេជានិច្ចមិនចេះសាបសូន្យទៅណាឡើយ ដ្បិតថាគ្រប់ពេលគ្រប់វេលាដែលគេចង់ប្រព្រឹត្តអំពើទុច្ចរិតនានា នោះគេនឹងមានសេចក្តីភ្ញាក់រឭកនឹកដល់ភ្លាមថាអំពើទាំងនោះមិនគាប់គួរនឹងប្រព្រឹត្ត មិនគួរមានចិត្តមិនស្មោះត្រង់និងបំផ្លាញកិត្តិយសខ្លួនឯងជាដើម។

## ៣.សេចក្តីបញ្ចប់

**វង្វាយតម្លៃ៖** ឆ្លងតាមការបកស្រាយខាងលើ ប្រធានបទនេះពិតជាមានអត្ថន័យអប់រំយ៉ាងសម្បូរបែបក្នុងការណែនាំ បង្ហាញផ្លូវឱ្យមនុស្សយល់ដឹងថាមានតែមនុស្សដែលប្រកាន់ខ្ជាប់នូវសេចក្តីសុចរិតទៀតត្រង់តែប៉ុណ្ណោះ ដែលអាចរស់នៅក្នុងសេចក្តីថ្លៃថ្នូរ ទទួលបានការគោរពនិងតម្លៃជាដរាប ព្រមទាំងបើទោះបីពួកគេស្ថិតក្នុងស្ថានភាពណាក៏ដោយ ក៏ពួកគេមិនងាយងាករកអំពើទុច្ចរិតឡើយ។

**មតិផ្ទាល់ខ្លួន ៖** ដូច្នេះក្នុងនាមជាមនុស្សម្នាក់ យើងគប្បីប្រកាន់យកតែអំពើសុខរិតទៀងត្រង់ យុត្តិធម៌ និងគោរពច្បាប់ឱ្យបានហ្មត់ចត់ ដើម្បីក្លាយជាពលរដ្ឋល្អនៅក្នុងសង្គមជាតិមួយនេះពោរពេញកិត្តិយស សេចក្តីថ្លៃថ្នូរ និងតម្លៃដូចបណ្តាសង្គមជាន់ខ្ពស់ដទៃទៀត។

**ប្រធាន៖** មានមតិមួយបានលើកឡើងថា “តួអង្គនាងកែកេសីគឺតំណាងឱ្យមនុស្សអាក្រក់នៅក្នុងសង្គម”។ចូរពន្យល់និងលើកអំណះអំណាងមកបញ្ជាក់ឱ្យបានច្បាស់លាស់។

**១.សេចក្តីផ្តើម**

- **លំនាំបញ្ហា៖** និយាយទាក់ទងនឹងប្រធាន
- **ចំណូលបញ្ហា៖** បញ្ចូលប្រធានបញ្ចូលទាំងស្រុង
- **ចំណោទបញ្ហា៖** តើមតិខាងលើនេះមានន័យយ៉ាងដូចម្តេច?

**២.តួសេចក្តី**

- **ឃ្លាភ្ជាប់សេចក្តី**
- **ពន្យល់ពាក្យគន្លឹះ**
  - តំណាង៖ មានន័យថាអ្នកដែលធ្វើអ្វីៗតាងឱ្យគេ។
  - សង្គម៖ ការប្រមូលផ្តុំរបស់ក្រុមមនុស្ស។
  - មនុស្សអាក្រក់៖ មនុស្សមានចរិតមិនល្អ ប្រព្រឹត្តតែអំពើបាប។
- **ពន្យល់ន័យប្រធាន**

ប្រធានបានន័យថា តួអង្គនាងកែកេសីជាតំណាងឱ្យមនុស្សអាក្រក់ព្រោះតែភាពលោភលន់របស់នាងបានធ្វើឱ្យមនុស្សជាច្រើនត្រូវច្របបញ្ហា។

- **បំណកស្រាយ**

ក.**បំភ្លឺគំនិតទូទៅ**

ជាការពិតណាស់នៅក្នុងសង្គមយើងបច្ចុប្បន្នគឺមានមនុស្សដែលអាក្រក់ច្រើនហើយសេចក្តីអាក្រក់ដែលពួកគេបានធ្វើគឺមានផលប៉ះពាល់ដល់និងអ្នកដទៃទៀត តែសេចក្តីអាក្រក់ខ្លះទៀតមិនមែនសុទ្ធតែប៉ះពាល់ទាំងអស់នោះទេ ព្រោះពេលខ្លះគ្រាន់តែភាពលោភលន់មួយពេលខ្វះការគិតពីប្រយោជន៍ខ្លួនរបស់គាត់ធំជាងអនាគតអ្នកដទៃ អ៊ីចឹងហើយចុងក្រោយគាត់ក៏ក្លាយជាមនុស្សអាក្រក់ដែលគេស្អប់ខ្ពើម។

**ខ.បំភ្លឺគំនិតប្រធាន**

ដូចបានដឹងហើយថាគំនិតរបស់ប្រធានគឺចង់បង្ហាញពីចរិតលក្ខណៈរបស់តួអង្គនាងកៃកេសីដែលនាងមានគំនិតអាក្រក់ ហើយតាមរយៈគំនិតអាក្រក់របស់នាងនេះដែលមានចរិតដូចគាត់គឺគិតតែប្រយោជន៍របស់ខ្លួនមិនគិតគេពីអារម្មណ៍របស់អ្នកដទៃ។

### គ.បំភ្លឺគំនិតនៅក្នុងអក្សរសិល្ប៍

តាមរយៈសិក្សារឿងរាមកេរ្តិ៍ យើងដឹងហើយនៅក្នុងរឿងមានតួអង្គច្រើនហើយតួនីមួយៗសុទ្ធតែមានចំណុចល្អនិងអាក្រក់រៀងៗខ្លួន មួយវិញទៀតតាមរយៈតួអង្គទាំងអស់គេលើកយកតួអង្គតែម្នាក់គឺនាងកៃកេសីដែលជាម្តាយរបស់ព្រះភិរុតយកមកនិយាយ ដោយសារតែអំពើអាក្រក់របស់នាងចង់ឱ្យកូនរបស់នាងបានឡើងសោយរាជ្យ ទើបនាងក្លាយជាមនុស្សម្នាក់ដែលខ្វះការគិតពិចារណាពោលគឺនៅត្រង់ចំណុចដែលនាងកៃកេសីបានដាក់ខសន្យាជាមួយនឹងព្រះបាទទសរថបើសិនជានាងអាចកម្ចាត់យក្សបាន គឺត្រូវព្រះភិរុតឡើងសោយរាជ្យ ហើយមិនព្រមឱ្យព្រះរាមដែលជាកូនច្បងឡើងសោយរាជ្យសម្បត្តិទេនោះបើគិតតាមច្បាប់កូនច្បងត្រូវឡើងសោយរាជ្យ មិនតែប៉ុណ្ណោះទេ នាងកៃកេសីក៏បានសុំឱ្យព្រះបាទទសរថដេញព្រះរាមចេញពីនគរឱ្យចូលទៅបួសនៅក្នុងព្រៃរយៈពេលដប់បួនឆ្នាំហើយនៅពេលដែលព្រះបាទទសរថបានធ្វើតាមសន្យារួចក៏ធ្វើឱ្យព្រះអង្គចូលទិវង្គត ដូចនេះហើយទង្វើរបស់នាងកៃកេសីពិតជាអាក្រក់មែនហើយនៅចុងបញ្ចប់នៃការលោភលន់របស់នាងដែលចង់ឱ្យកូនបានល្អនោះ គឺមិនបានធ្វើឱ្យនាងល្អប្រសើរអ្វីទេមានតែឱ្យភិរុតដែលជាកូនកាន់តែស្អប់នាងលើសដើម ចុងក្រោយមានតែធ្វើឱ្យនាងមានអារម្មណ៍ថាតែស្តាយនៅទង្វើរដែលនាងបានធ្វើតែប៉ុណ្ណោះ។

- **សរុបមតិ៖** ជារួមមកតាមការបកស្រាយមតិខាងលើបានបង្ហាញពីតួអង្គនាងកៃសីគឺតំណាងឱ្យមនុស្សអាក្រក់នៅក្នុងសង្គមពិតប្រាកដមែន។

## ៣.សេចក្តីបញ្ចប់

- **វង្វាយតម្លៃ៖** មតិខាងលើពិតជាមានន័យនិងខ្លឹមសារបង្កប់នូវតម្លៃអប់រំដើម្បីឱ្យមនុស្សយើងម្នាក់ៗ មុននឹងធ្វើអ្វីមួយ មិនត្រូវលោភលន់នោះទេ នៅចុងក្រោយគឺមានតែខាតពេលវេលាឥតប្រយោជន៍ហើយមានឈ្មោះជាមនុស្សក្រក់ទៀតផង។

**មតិផ្ទាល់ខ្លួន ៖** លើកឡើងនូវការប្តេជ្ញាចិត្ត...។

# វិញ្ញាសាត្រៀមប្រឡងមធ្យមសិក្សាទុតិយភូមិ

## ប្រធានអត្ថាធិប្បាយពន្យល់

**ប្រធាន** ៖ មតិមួយបានពោលថា “**ការគោរពសិទ្ធមនុស្ស គឺលើកកម្ពស់ដល់ការអភិវឌ្ឍសង្គម**” ។ ចូរលើកឧទាហរណ៍មកបញ្ជាក់។

### គម្រោងតែង

### ១.ផ្ដើមសេចក្ដី

-**លំនាំបញ្ហា៖** តាមរយៈការរស់នៅក្នុងសង្គមការចេះឱ្យតម្លៃទៅលើមនុស្សជាតិដូចគ្នាក្ដី ជាតិសាសន៍ដទៃក្ដីនឹងធ្វើឲ្យមានការរីកចម្រើន។(៥ពិន្ទុ)

-**ចំណូលបញ្ហា៖** (បង្ហាញប្រធាន) : ហេតុដូចនេះហើយទើបមានមតិមួយបានពោលថា« ការគោរពសិទ្ធមនុស្ស គឺលើកតម្កើងដល់ការអភិវឌ្ឍសង្គម»។(២ពិន្ទុ)

-**ចំណោទបញ្ហា៖** តើទស្សនៈខាងលើនេះមានអត្ថន័យយ៉ាងណាខ្លះ?(៣ពិន្ទុ)

### ២.តួសេចក្ដី(៥០ពិន្ទុ)

- **ឃ្លាភ្ជាប់សេចក្ដី៖** ដើម្បីជាប្រទីបដល់ការបំភ្លឺដល់ការបកស្រាយប្រធានខាងលើនេះ យើងគួរគប្បីសិក្សាស្វែងយល់នូវពាក្យគន្លឹះជាំមុនសិន។(១ពិន្ទុ)
- **ពន្យល់ពាក្យ (២ពិន្ទុ)**
  - **គោរព៖** ដំណើរប្រតិបត្តិតាមសសេចក្ដីកោតក្រែង ។
  - **អភិវឌ្ឍ៖** ចម្រើនក្រៃលេង ។
- **ពន្យល់ន័យ៖** ប្រធានមានន័យថា កាលណាយើងរស់នៅក្នុងសង្គមមួយប្រទេសមួយ ជាតិមួយមានការគោរពគ្នា ចេះអធ្យាស្រ័យដល់គ្នាគឺជាហេតុដែលជួយធ្វើឲ្យប្រទេស មានការរីចម្រើន ។(២ពិន្ទុ)
- **បកស្រាយ៖** “មនុស្សរស់នៅក្នុងសង្គមជាមួយគ្នាគោរពគ្នាទៅវិញទៅមកជួយឲ្យសង្គម មានការរីកចម្រើន”
  - **គំនិតសំខាន់(២០ពិន្ទុ)**

- គោរពសិទ្ធមនុស្សជាតិដូចគ្នា
- គោរពស្រលាញ់អន្តរជាតិក្នុងការមិនរើសជាតិសាសន៍
- ប្អូនគោរពសិទ្ធបង
- គោរពសិទ្ធស្រ្តី

➢ **ឧទាហរណ៍(២០ពិន្ទុ)**

- រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖ លោករដ្ឋមន្ត្រីវ័យក្មេងគោរពសិទ្ធមនុស្សជាតិដូចគ្នាក្នុងនាមជារដ្ឋមន្ត្រីក៏ដោយមិនមើលងាយដល់រូបសម ។
- រឿងតេជោមាសតេជោយ៉ត : តេជោយ៉តគោរពស្រលាញ់ជំទាវស្រែន។
- រឿងរាមកេរ្តិ៍៖ ព្រះលក្ខណ៍គោរពស្រលាញ់ចំពោះព្រះរាម ។
- រឿងកុលាបប៉ៃលិន៖ ចៅចិត្រគោរពស្រលាញ់នាងឃុននារីមិនមើលងាយដល់នារី ។

- **សរុប**៖ តាមហេតុផលដូចខាងលើនេះហើយបញ្ជាក់ថា ការគោរដល់សិទ្ធមនុស្សពិតជាការធ្វើឲ្យប្រទេសជាតិរីកចម្រើនតាមរយៈមនុស្សចេះសាមគ្គីដល់មនុស្សជាតិដូចគ្នា ។(៥ពិន្ទុ)

**៣.បញ្ចប់សេចក្តី(១០ពិន្ទុ)**

- **វាយតម្លៃប្រធាន**៖ មតិខាងលើនេះពិតជាមានអត្ថន័យសំខាន់ ក្នុងការធ្វើឲ្យមនុស្សចេះគោរពដល់សិទ្ធមនុស្សដូចគ្នា ទើបធ្វើឲ្យមានការលូតលាស់រីកចម្រើន ។
- **មតិផ្ទាល់ខ្លួន**៖ ដូច្នេះក្នុងនាមជាអ្នកសិក្សា យើងគប្បីចេះប្រកាន់យកការគោរពសិទ្ធមនុស្សដូចគ្នាទើបជីវិតនៅក្នុងសង្គមមានការអភិវឌ្ឍ ។(៨ពិន្ទុ)

  **រចនាបថ(៥ពិន្ទុ)**

  - អក្សរ អក្ខរាវិរុទ្ធ ឃ្លាល្បះ(២ពិន្ទុ)
  - លំនាំសំណេរល្អ(៣ពិន្ទុ)

ប្រធានៈ មតិមួយលើកឡើងថា “**ការសម្រេចចិត្ត របស់ពុទ្ធិសែនក្នុងការចាកចេញពីនាងកង្រី ជាដំណោះស្រាយមួយដ៏ប្រសើរ**”។ ចូរពន្យល់ដោយលើកឧទាហរណ៍មកបញ្ជាក់ ។

## គម្រោងតែង

## ១.សេចក្តីផ្តើម

- **លំនាំបញ្ហា៖** ការសម្រេចចិត្តរបស់តួអង្គនៅក្នុងរឿងនីមួយៗសុទ្ធតែអ្នកនិពន្ធឬអ្នកនិទានបានគិតច្បាស់ហើយទើបត្រូវឲ្យតួរឿងធ្វើតាមការសម្រេចចិត្តនូវរឿងមួយច្បាស់។(៥ពិន្ទុ)
- **ចំណូលបញ្ហា៖** (បង្ហាញប្រធាន) : ហេតុដូច្នេះហើយទើបមានមតិមួយបានពោលថា «ការសម្រេចចិត្តរបស់ពុទ្ធិសែន ក្នុងការចាកចេញពីកង្រីគឺជាដំណោះស្រាយមួយដ៏ប្រសើរ» ។(២ពិន្ទុ)
- **ចំណោទបញ្ហា៖** តើទស្សនៈខាងលើនេះមានអត្ថន័យយ៉ាងណាខ្លះ ?(៣ពិន្ទុ)

## ២.តួសេចក្តី(៥០ពិន្ទុ)

- **ឃ្លាភ្ជាប់សេចក្តី៖** ដើម្បីជាប្រទីបបំភ្លឺដល់ការបកស្រាយប្រធាបខាងលើនេះ យើងគួរគប្បីសិក្សាស្វែងយល់ពាក្រគន្លឹះជាមុនសិន ។
- **ពន្យល់ពាក្យ(២ពិន្ទុ)**
- **ការសម្រេចចិត្ត** ៖ គឺជាការធ្វើរឿងអ្វីមួយតាមឆន្ទៈរបស់ខ្លួនផ្ទាល់ ។
- **ដំណោះស្រាយ៖** រកវិធីសាស្រ្តណាមួយឲ្យចាកចេញពីស្ថានភាពលំបាកទៅដល់កន្លែងមួយដែលល្អប្រសើរបមផុត ។
- **ពន្យល់ន័យ៖** ប្រធាបនេះមានន័យថា ការដែលពុទ្ធិសែនបានធ្វើការសម្រេចចិត្តចាលចេញពីកង្រីបែបនេះធ្វើឲ្យមានភាពប្រសើរបំផុត ។
- **បកស្រាយប្រធាន៖** ការចាកចេញរបស់ពុទ្ធិសែនគឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវ

➢ **គំនិតសំខាន់(២០ពិន្ទុ)**

- មិនធ្វើឲ្យកើតសង្គ្រាមរវាងយក្សនិងពុទ្ធិសែន

- បានជួយម្ដាយនិងម្ដាយធំដែលពិការភ្នែកជាមនុស្សដែលមិនយកស្ដីជាធំនាំប៉ះពាល់ដល់អាយុជីវិត
- ចេះមើលស្ថានការនិងពេលវេលា
- មិនយកមនោសញ្ចេតនាជាចម្បង ។

➢ **ឧទាហរណ៍(២០ពិន្ទុ)**

- រឿងពុទ្ធិសែននាងកង្រី
- **សរុបសេចក្ដី** ការសម្រេចចិត្តរបស់ពុទ្ធិសែនគឺជាការសម្រេចចិត្តដ៏ល្អមួយពិតមែនព្រោះកូនត្រូវដឹងគុណដល់មាតាបិតាជាចាំបាច់ ។(៥ពិន្ទុ)

**៣.បញ្ចាប់សេចក្ដី(១០ពិន្ទុ)**

– **វាយតម្លៃប្រធាន៖** មតិខាងលើពិតជាមានអត្ថន័យសំខាន់ ព្រោះពុទ្ធិសែនបានធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ។

– **មតិផ្ទាល់ខ្លួន៖** ដូច្នេះក្នុងនាមជាអ្នកសិក្សាយើងគប្បីគួរយកគម្រូដល់ពុទ្ធិសែនដែលមិនគិតតែពីក្ដីសុខខ្លួនផ្ទាល់។(៥ពិន្ទុ)

**៤. រចនាបថ(៥ពិន្ទុ)**

- អក្សរ អក្ខរាវិរុទ្ធ ឃ្លាល្បះ(២ពិន្ទុ)
- លំនាំសំណេរល្អ(៣ពិន្ទុ)

ប្រធានមួយលើកឡើងថា “**ការរស់នៅក្នុងសង្គមត្រូវមានសីលធម៌ ការធ្វើល្អត្រូវផ្ដើមចេញពីចិត្ត**” ។ ចូរបកស្រាយនិងលើកឧទាហរណ៍មកបញ្ជាក់ ។

## គម្រោងតែង

**១.សេចក្ដីផ្ដើម**

– **លំនាំបញ្ហា៖** និយាយទាក់ទងនិងប្រធាន

– **ចំណោលបញ្ហា៖** បញ្ចូលប្រធានបទ

– **ចំណោទបញ្ហា៖** តើពំនោលខាងលើមានអត្ថន័យ...?

**២.តួសេចក្តី**

– **ឃ្លាភ្ជាប់សេចក្តី៖** ដើម្បីឲ្យមានភាពងាយស្រួលក្នុងការបកស្រាយមតិខាងលើឲ្យបានក្បោះក្បាយជាដំបូងយើងគួរស្វែងយល់នូពាក្យគន្លឹះមួយចំនួនជាមុនសិន ។

➢ **ពន្យល់ពាក្យគន្លឹះ**

- **សង្គម៖** មានន័យថាការប្រមូលរួបរួមផ្តុំមនុស្ស បណ្តុំនៃមនុស្ស ។
- **សីលធម៌៖** គឺសម្តៅដល់កិរិយាមារយាទ សណ្តាប់ធ្នាប់ ដំបូន្មានដែលនាំឲ្យចៀសវាងអំពើអាក្រក់ ។
- **ចិត្ត៖** ធម្មជាតិសម្រាប់សន្សំអារម្មណ៍ សភាវៈសម្រាប់គិត។

– **ពន្យល់ន័យប្រធាន៖** ប្រធាននេះមានន័យថា ជាធម្មតាមនុស្សដែលរស់នៅក្នុងសង្គមត្រូវរស់នៅប្រកបដោយសីលធម៌ អាកប្បកិរិយាសមរម្យល្អ ទើបជាទីគោរពរាប់អានរបស់មនុស្សទាំងឡាយនៅក្នុងសង្គមទាំងមូល ។ មួយទៀតការប្រាកដកិច្ចការត្រូវធ្វើដោយស្មោះសរប្រកបដោយសេចក្តីព្យាយាមពិតប្រាកដ ។

– **បកស្រាយប្រធាន៖**

**ក. បំភ្លឺគំនិតទូទៅ៖**

ដោយឆ្លងកាត់បទពិសោធន៍ពិតស្ថិតនៅក្នុងសង្គមសព្វថ្ងៃ បានបង្ហាញនូវសកម្មភាពពិតរបស់មនុស្សនៅក្នុងសង្គម មានការខិតខំប្រកបកិច្ចការ មានសេចក្តីព្យាយាមធ្វើការងារដោយយកចិត្តទុកដាក់ ព្រមទាំងដោយអាកប្បកិរិយាមារយាទ ប្រកាន់ក្រមសីលធម៌ គោរពទៅតាមច្បាប់របស់សង្គមរបស់ការងារផងដែរ ។

**ខ. បំភ្លឺគំនិតប្រធាន ៖**

➢ ដូចបានបង្ហាញខាងលើរួចមកហើយ ៖

- ការរស់នៅក្នុងសង្គមត្រូវមានសីលធម៌ មនុស្សរស់នៅក្នុងសង្គមរស់ដើម្បីឲ្យមានសុភមង្គលមានការរាប់អានគោរពស្រលាញ់អំពីសំណាក់របស់មហាជនត្រូវមានសីលធម៌ ចរឹកលក្ខណៈល្អ ចេះយកអាសារអ្នកដទៃ...។

**ឧទាហរណ៍៖** នៅក្នុងរឿងរាមកេរ្តិ៍ ព្រះរាមជាអ្នកមានចំណេះដឹង ចេះជួយអ្នកដទៃ មានចិត្តសណ្ដោស អាកប្បកិរិយាសមស្របទៅវប្បធម៌ ច្បាប់ទម្លាប់របស់សង្គម គោរពទៅតាមច្បាប់ជាតិ មិនបៀតបៀនអ្នកដទៃ ដែលជាហេតុធ្វើឲ្យប្រជានុរាស្រ្តមានសេចក្ដីពេញចិត្តចំពោះទ្រង់…។

**ឧទាហរណ៍៖** រឿងមាលាដួងចិត្ត នៅពេលដែលទីឃាវុធជួយយកអាសារលោកទេពកោសល្យ ត្រង់នេះបានបញ្ជាក់យ៉ាងច្បាស់ថា ទីឃាវុធជាមនុស្សចេះជួយយកអាសារចំពោះអ្នកដទៃ មួយវិញទៀតនៅពេលដែលទីឃាវុធនៅលើរថភ្លើងបាននិយាយពាក្យសម្ដីប្រកបដោយសីលធម៌ ត្រង់នេះបានបង្ហាញថាទីឃាវុធជាមនុស្សដែលមិនឆ្មើងឆ្មៃ…។

- ការធ្វើល្អត្រូវផ្ដើមចេញពីចិត្ត នៅទីនេះមានន័យថាការងារទាំងឡាយប្រសិនបើចង់ឲ្យសម្រេចបានល្អ លុះត្រាតែធ្វើប្រកបដោយចិត្ត នៅពេលណាមនុស្សមានជំនឿចិត្តលើខ្លួនឯង មានការតាំងចិត្តការងារនោះទើបបានសម្រេចដោយល្អ…។

**ឧទាហរណ៍៖** រឿងកុលាបប៉ៃលិន ចៅចិត្រជាមនុស្សធ្វើការងារប្រកបដោយការតាំងចិត្តខ្ពស់ ហ៊ានជំនះឧបសគ្គគ្រប់សព្វបែបយ៉ាង មានការព្យាយាមតាំងពីកម្មករត្បូងរហូតដល់អ្នកគ្រប់គ្រងកម្មករ…។

**ឧទាហរណ៍៖** រឿងមាយើង ក្រោមការណែនាំរបស់ប្រពន្ធ មាយើងមានការជំនះនឹងឧបសគ្គគ្រប់បែបយ៉ាងដើម្បីសម្រេចគោលបំណង ព្រមទាំងការងាររបស់ខ្លួនមិនគិតពីការនឿយហត់ នេះក៏ដោយសារតាំងចិត្តព្យាយាមដោយពិតផងដែរ…។

**៣. សេចក្ដីបញ្ចប់**

**វាយតម្លៃប្រធាន៖** ពំនោលខាងលើពិតជាមានតម្លៃក្នុងការអប់រំដល់មនុស្សគ្រប់រូបឱ្យមានសេចក្ដីតាំងចិត្តព្យាយាម ហ៊ានជំនះរាល់ឧបសគ្គគ្រប់បែបយ៉ាងដើម្បីសម្រេចគោលបំណងរបស់ខ្លួន។ រាល់ការងារទាំងអស់ត្បិតតែមានការព្យាយាម ក៏ប៉ុន្តែក៏ត្រូវមានសីលធម៌ គោរពច្បាប់សង្គមជាតិ គោរពសិទ្ធិរបស់អ្នកដទៃ…។

**ប្រធាន៖** សុភាសិតមួយលើកឡើងថា **"ទុកដាក់កូនចៅឱ្យមើលផៅសណ្ដាន"**។ ចូរបកស្រាយ និងលើកឧទាហរណ៍មកបញ្ជាក់។

**គម្រោងតែង**

**១. សេចក្ដីផ្ដើម**

- **លំនាំបញ្ហា៖** និយាយទាក់ទងនឹងប្រធាន
- **ចំណូលបញ្ហា៖** បញ្ចូលប្រធាន...។
- **ចំណោទបញ្ហា៖** តើពំនោលខាងលើមានអត្ថន័យ...។

**២. តួសេចក្ដី**

- **ឃ្លាភ្ជាប់សេចក្ដី៖** ដើម្បីជាស្ពានឈានទៅរកការបកស្រាយប្រធានខាងលើ យើងគួរគប្បីឈ្វេងយល់ សិក្សាពាក្យគន្លឹះមួយចំនួនសិន។
- **ពន្យល់ពាក្យ៖**

**ទុកដាក់៖** គឺជាការរៀបចំអ្វីមួយឱ្យគង់ រក្សាអ្វីមួយឱ្យបានល្អ ឱ្យបានគង់វង្ស

**សណ្ដាន៖** ជាផៅពង្ស វង្សត្រកូល

**ពន្យល់ន័យប្រធាន៖** សុភាសិតខាងលើមានន័យថា មុននឹងរៀបចំកូនចៅឱ្យក្លាយជាស្វាមីភរិយារបស់អ្នកណា ឬក៏គ្រួសារឯណាមួយត្រូវមើលទៅគ្រួសារ បង ប្អូន សាច់ញាតិរបស់គេជាមុនសិន។

- **បកស្រាយប្រធាន៖**

**ក. បំភ្លឺគំនិតទូទៅ**

ដោយឆ្លងកាត់ការមើលទៅតាមតថៈរបស់មនុស្សសព្វថ្ងៃបានឱ្យយើងឃើញថា នៅក្នុងគ្រួសារមួយតែងតែមានឪពុកម្ដាយនិងកូនៗ។ ហើយកូនទាំងឡាយជាអ្នករៀន ត្រាប់តាមឪពុកម្ដាយដែលគេតែងតែនិយាយថាតំណពូជ ឬហ្សែន។ នៅពេលណាដែលឪពុកម្ដាយជាអ្នកដែលប្រព្រឹត្តរឿងមិនល្អ កូនចៅក៏ប្រព្រឹត្តស្រដៀងនឹងគ្នាដែរ។

**ខ. បំភ្លឺគំនិតប្រធាន**

ដូចដែលបានបង្ហាញពីខាងលើរួចមកហើយ

- ទុកដាក់កូនចៅឱ្យមើលផៅសណ្ដាន មានន័យថាឪពុកម្ដាយជាអ្នកដែលបង្កើតកូនគ្រប់រូបត្រូវមានសេចក្ដីឈឺឆ្អាលចំពោះការរៀបចំទុកដាក់កូនចៅឱ្យមានគូស្វាមីភរិយា

ទោះជានៅក្នុងច្បាប់ក្រោមរដ្ឋប្បវេណី មិនមានមាត្រាណាមួយបានចែងថាឪពុកម្តាយមានសិទ្ធិក្នុងការរៀបចំទុកដាក់កូនចៅក៏ដោយ ក៏ប៉ុន្តែយើងដឹងមកហើយថាកាត់ទឹកមិនដាច់ កាត់សាច់មិនកើត ដូច្នេះហើយឪពុកម្តាយឈឺឆ្អាលចំពោះកូនចៅគឺជារឿងធម្មតា។ ហើយក្នុងការរៀបចំកូនចៅនោះទៀតសោត ក៏ត្រូវមើលច្បាប់ទម្លាប់នៃគ្រួសាររបស់ភាគីម្ខាងទៀតដែរ...។

**ឧទាហរណ៍៖** នៅក្នុងរឿងផ្កាស្រពោន យាយនួនដែលជាម្តាយរបស់វិធាវីបានលើកវិធាវីទៅឱ្យចៅណៃសិត ដែលជាកូនរបស់ចៅកែកាណ្វតជាអ្នកមានមុខមាត់នៅក្នុងស្រុកភូមិ ដោយមើលទៅលើឋានៈ គ្រួសារ...។

**ឧទាហរណ៍៖** នៅក្នុងរឿងទុំទាវ នៅក្នុងរឿងនេះផងដែរ យាយផាន់បានលើកទាវទៅឱ្យម៉ឺនងួន ដែលជាកូនរបស់អរជូនជាស្តេចត្រាញ់ ដោយមានបំណងចង់ឱ្យទាវមានមុខមាត់នៅក្នុងសង្គម និងមានជីវភាពល្អប្រសើរ ប្រកបដោយសេចក្តីថ្លៃថ្នូរ និងការគោរពពីសំណាក់របស់មហាជន...។

## ៣. បញ្ចប់សេចក្តី

- **វាយតម្លៃប្រធាន៖** ពំនោលខាងលើពិតជាមានតម្លៃក្នុងការអប់រំមនុស្ស ជាពិសេសមាតាបិតាឱ្យចេះជ្រើសរើសគូស្រករដោយការយកចិត្តទុកដាក់ មិនឱ្យធ្វេសប្រហែសក្នុងការរកគូស្រកររបស់ខ្លួន។ មុននឹងជ្រើសរើសត្រូវមើលទៅកាន់ភាគីម្ខាងទៀត ទាំងចំណេះវិជ្ជា ទ្រព្យសម្បត្តិ កាយសម្បទារ សម្រស់ ព្រមទាំងអាកប្បកិរិយា...។

## ៣.២.វិញ្ញាសាត្រៀមប្រឡង២០២០

**ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**
**សម័យប្រឡង ៖ ២១ ធ្នូ ២០២០**
**វិញ្ញាសា ៖ អក្សរសាស្ត្រខ្មែរ ( វិទ្យាសាស្ត្រពិត )**
**រយៈពេល ៖ ៩0 នាទី**
**ពិន្ទុសរុប ៖ ៧៥**

ប្រធាន ៖ កវីព្រះរាជសម្ភារបានថែងថា « ខ្លែងហើរត្បិតខ្យល់ » ។ ចូរអធិប្បាយពន្យល់ដោយភ្ជាប់ជាមួយឧទាហរណ៍ពីក្នុងស្នាដៃនៃរឿងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់ ។

អត្រាកំណែ

1. **សេចក្តីផ្តើម ( 10 pts )**

ក. លំនាំបញ្ហា ( 4 pts )

ខ. ចំណូលបញ្ហា ( 3 pts )

គ. ចំណោទបញ្ហា ៖ តើមតិខាងលើមានខ្លឹមសារអប់រំដូចម្តេចខ្លះ ? ( 3 pts )

2. **តួសេចក្តី ( 50 pts )**

ក. ឃ្លាភ្ជាប់សេចក្តី ( 1 pts )

ខ. ពន្យល់ពាក្យគន្លឹះ ( 2 pts )

- ខ្លែង : វត្ថុម្យ៉ាងដែលគេចងខ្សែហើយកន្ទ្រាក់បង្ហោះទៅលើអាកាសនារដូវខ្យល់ធ្លាក់ ។
- ខ្យល់ : សភាវៈធម្មជាតិដែលទ្រទ្រង់ដល់ការកួចបំប៉ើង ។

គ. ពន្យល់ន័យប្រធាន ( 2 pts )

ឃ. បំណាកស្រាយ ( 40 pts )

១. គំនិតសំខាន់ ៖ ខ្លែងហើរត្បិតខ្យល់ ( 20 pts )

+ ន័យចំ ( 10 pts )

- ជាទូទៅ គេបង្ហោះខ្លែងនៅរដូវមានខ្យល់ធ្លាក់ ...

- ខ្លែងផ្តុំពីកំណាត់ចង់ប្លាស្ទិច ចម្រៀកឫស្សី និងខ្សែអំបោះស្វិត ដែលមានទម្ងន់សមាមាត្រគ្នា ដើម្បីបណ្តែតខ្លួនក្នុងចរន្តខ្យល់កួច
- សរីរាង្គខ្លែង មានក្បាល ខ្លួន ត្រចៀក និងកន្ទុយ
- ខ្លែងហើររេរាំរស់រវើកលើអាកាស ហើយសំឡេងខ្លែងកូតជាមួយខ្យល់ឮដូចតន្ត្រីម្យ៉ាងដែរ
- បើគ្មានខ្យល់ ទោះខ្លែងផ្តុំត្រូវតាមក្បួនយ៉ាងណាក៏មិនអាចហោះបានដែរ
- ពេលខ្លែងរក្សាលំនឹងបានក្នុងខ្យល់ ស្រាប់តែស្ងប់ខ្យល់ ខ្លែងនឹងធ្លាក់មកដី
- បើខ្យល់ខ្លាំង ភ្លៀងព្យុះ នោះខ្លែងនឹងដាច់រហែកអស់
- .................................. ។

+ ន័យធៀប ( 10 p t s )
- ខ្លែង ប្រដូចនឹង មនុស្សគ្រប់ស្រទាប់វណ្ណៈទាំងអស់ ក្មេងចាស់ ប្រុសស្រី អ្នកធំ អ្នកខ្សោយ មានក្រ ...
- សម្រស់ហោះហើនៃខ្លែង ប្រៀបបាននឹង ភាពជោគជ័យរបស់មនុស្ស គឺទ្រព្យសម្បត្តិ កិត្តិយស ក្តីសុខ ទំនុកចិត្ត ការផ្តល់តម្លៃ ...
- ខ្យល់ សំដៅដល់ ភាគីជាដៃគូ អ្នកជួយជ្រោមជ្រែង អ្នកឧបត្ថម្ភគាំទ្រ ...
- មនុស្សក្នុងសង្គមត្រូវការប្រាស្រ័យទាក់ទងគ្នា ជួយគ្នា ការពារគ្នាទៅវិញទៅមក ...
- មនុស្សមិនអាចរស់នៅតែឯកឯងបានទេ
- បើមនុស្សភ្លេចខ្លួន អាងតែជំនួយ លុះអស់ពីជំនួយ នឹងវិលមកសភាពដើមវិញ
- បើជួយខុសមនុស្ស ធ្វើឱ្យមនុស្សកាន់តែខ្ជិល មិនរីកចម្រើនឡើយ
- ............................. ។

២. អំណះអំណាងក្នុងរឿងអក្សរសិល្ប៍ខ្មែរ ( 20 p t s )
- រឿង រាមកេរ្តិ៍ ៖ ព្រះរាមសិក្សាចប់គម្ពីរត្រៃវេទដោយសារមានឥសីពិស្វាមិត្របង្រៀន
- រឿង មហាវេស្សន្តរជាតក ៖ ព្រះនាងមទ្រី និងបាជាលីក្រឹស្នាជួយបំពេញទានបារមីថ្វាយព្រះវេស្សន្តរ
- រឿង ទុំទាវ ៖ ព្រះបាទរាមាតែងតាំងទុំជាម៉ឺនឯកផ្នែកតូរ្យតន្ត្រី
- រឿង កុលាបប៉ៃលិន
- រឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់
- ............................ ។

ង. សរុបមតិ ( 5pts )

**3. សេចក្តីបញ្ចប់ ( 10pts )**

ក. វង្វាយតម្លៃប្រធាន ( 6pts )

ខ. ទស្សនៈផ្ទាល់ខ្លួន ( 4pts )

**4. រចនាបថ ( 5pts )**

## ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
## សម័យប្រឡង ៖ ២១ ធ្នូ ២០២០
## វិញ្ញាសា ៖ អក្សរសាស្ត្រខ្មែរ ( វិទ្យាសាស្ត្រសង្គម )
## រយៈពេល ៖ ១៥០ នាទី
## ពិន្ទុសរុប ៖ ១២៥

ប្រធាន ៖ គេថា « ការងារនាំមនុស្សឱ្យមានសេចក្តីថ្លៃថ្នូរ » ។ ចូរបកស្រាយដោយលើកអំណះអំណាងពិក្អុងតថភាពសង្គមបច្ចុប្បន្ន និង រឿងអក្សរសិល្ប៍ខ្មែរ ។

អត្រាកំណែ

**1. សេចក្តីផ្តើម ( 15pts )**

ក. លំនាំបញ្ហា ( 7pts )

ខ. ចំណូលបញ្ហា ( 4pts )

គ. ចំណោទបញ្ហា ៖ តើមតិខាងលើមានអត្ថន័យខ្លឹមសារដូចម្តេចខ្លះ ? ( 4pts )

**2. តួសេចក្តី ( 85pts )**

ក. ឃ្លាភ្ជាប់សេចក្តី ( 2pts )

ខ. ពន្យល់ពាក្យគន្លឹះ ( 4pts )

- ការងារ : ការប្រកបរបររកស៊ីទទួលទានចិញ្ចឹមជីវិតប្រចាំថ្ងៃ ។
- សេចក្តីថ្លៃថ្នូរ : ការទទួលបានអ្នកដទៃគោរពរាប់អាន ។

គ. ពន្យល់ន័យប្រធាន ( 4pts )

ឃ. បំណកស្រាយ ( 65 pts )

១. គំនិតសំខាន់ ៖ ការងារនាំមនុស្សឱ្យមានសេចក្តីថ្លៃថ្នូរ ( 20 pts )

- ជាទូទៅ ក្នុងជីវភាពប្រចាំថ្ងៃមនុស្សត្រូវប្រកបការងារដើម្បីចិញ្ចឹមជីវិតរស់នៅ ...
- ការងារមានដូចជា កសិកម្ម សិប្បកម្ម ពលកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម សិល្បៈ មន្ត្រីរាជការ ...
- ជាការងារសុចរិត ស្របច្បាប់ បំពេញតាមតម្រូវការសង្គម ស្របតាមឧបនិស្ស័យ ចំណូលចិត្តខ្លួន ...
- បង្កើតបានទំនាក់ទំនង ការសាមគ្គី ជួយគ្នា គោរពរាប់អាន ផ្តល់តម្លៃ មានកិត្តិយស ឋានៈតួនាទី ...
- .............................. ។

២. អំណះអំណាង ( 45 pts )

+ ក្នុងតថភាពសង្គមបច្ចុប្បន្ន ៖ កាលណាមនុស្សមានការងារធ្វើ តែងមានគេស្គាល់រាប់អានច្រើន មានកិត្តិយស ............. ។

+ ក្នុងរឿងអក្សរសិល្ប៍ខ្មែរ

- រឿង ទុំទាវ ៖ ទុំទទួលងារជាម៉ឺនឯកផ្នែកតូរ្យតន្ត្រីព្រោះមានទេពកោសល្យសិល្បៈចម្រៀង
- រឿង កុលាបប៉ៃលិន ៖ ចៅចិត្រជាកម្មការមានសមត្ថភាពក្លាយជាសេដ្ឋីត្បូង
- រឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់ ៖ សួនសមជាកសិករគំរូក្លាយជាគណៈកម្មការកងឃុំ
- រឿង តេជោយ៉ត ៖ យ៉តក្លាហានពូកែក្បាច់គុនក្លាយជាមេទ័ព
- ........................... ។

ង. សរុបមតិ ( 10 pts )

**3. សេចក្តីបញ្ចប់ ( 15 pts )**

ក. វង្វាយតម្លៃប្រធាន ( 8 pts )

ខ. ទស្សនៈផ្ទាល់ខ្លួន ( 7 pts )

**4. រចនាបថ ( 10 pts )**

**ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**

**សម័យប្រឡង ៖ ២១ ធ្នូ ២០២០**

**វិញ្ញាសា ៖ អក្សរសាស្ត្រខ្មែរ** ( **វិទ្យាសាស្ត្រពិត** )

**រយៈពេល ៖ ៩០ នាទី**

**ពិន្ទុសរុប ៖ ៧៥**

<u>ប្រធាន</u> ៖ ពាក្យចាស់ពោលថា « ចំណេះជាអាហារ ប្រាជ្ញាជាអាវុធ » ។ ចូរស្រាយបំភ្លឺដោយលើកឧទាហរណ៍ក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ ។

<u>អត្រាកំណែ</u>

1. **សេចក្តីផ្តើម ( 10 pts )**

ក. លំនាំបញ្ហា ( 4 pts )

ខ. ចំណោលបញ្ហា ( 3 pts )

គ. ចំណោទបញ្ហា ៖ តើពំនោលខាងលើមានខ្លឹមសារអប់រំដូចម្តេចខ្លះ ? ( 3 pts )

2. **តួសេចក្តី ( 50 pts )**

ក. ឃ្លាភ្ជាប់សេចក្តី ( 1 pts )

ខ. ពន្យល់ពាក្យគន្លឹះ ( 2 pts )

- ចំណេះ
- ប្រាជ្ញា

គ. ពន្យល់ន័យប្រធាន ( 2 pts )

ឃ. បំណកស្រាយ ( 40 pts )

១. គំនិតសំខាន់ ៖ ចំណេះជាអាហារ ប្រាជ្ញាជាអាវុធ ( 20 pts )

- ចំណេះជាអាហារ

- ចំណេះផ្នែក វប្បធម៌ សីលធម៌ គុណធម៌ វិទ្យាសាស្ត្របច្ចេកទេស ការងារ មុខរបរ ...

- កាលណាមានចំណេះ នឹងមានការងារធ្វើ ...
- កម្រៃនៃការងារអាចដោះស្រាយជីវភាព ពិសេសស្បៀងអាហារសម្រាប់បន្តការងារ ...

- ប្រាជ្ញាជាអាវុធ

- ភាពវៃឆ្លាត គំនិតច្នៃប្រឌិត ដឹងខុស ដឹងត្រូវ ...
- អាចសិក្សាស្រាវជ្រាវរកឃើញបញ្ហា ...
- រកដំណោះស្រាយបញ្ហា ពិសេសដោះស្រាយភាពរង្វេងលង់ខ្លៅ ...

២. អំណះអំណាងក្នុងរឿងអក្សរសិល្ប៍ខ្មែរ ( 20 pts )

- រឿង រាមកេរ្តិ៍ ៖ ព្រះរាមប្រកាន់ធម៌អហិង្សា ...
- រឿង មហាវេស្សន្តរជាតក ៖ ព្រះវេស្សន្តរប្រកាន់លទ្ធិប្រជាធិបតេយ្យ ...
- រឿង ទុំទាវ ៖ នេនទុំចេះសិល្បៈច្រៀង ...
- រឿង កុលាបប៉ៃលិន ៖ ចៅចិត្រចេះពលកម្ម ...
- រឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់ ៖ សួនសមចេះកសិកម្ម ...
- ............................ ។

ង. សរុបមតិ ( 5 pts )

**3. សេចក្តីបញ្ចប់ ( 10 pts )**

ក. វង្វាយតម្លៃប្រធាន ( 6 pts )

ខ. ទស្សនៈផ្ទាល់ខ្លួន ( 4 pts )

**4. រចនាបថ ( 5 pts )**

## ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
## សម័យប្រឡង ៖ ២១ ធ្នូ ២០២០
## វិញ្ញាសា ៖ អក្សរសាស្ត្រខ្មែរ ( វិទ្យាសាស្ត្រសង្គម )
## រយៈពេល ៖ ១៥០ នាទី
## ពិន្ទុសរុប ៖ ១២៥

ប្រធាន ៖ ពុទ្ធោវាទចែងថា « មុសាវាទជាអាទិ៍នៃបាបកម្ម » ។ ចូរបកស្រាយដោយយកអំណះអំណាងក្នុងរឿងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់ ។

អត្ថាកំណែ

1. **សេចក្តីផ្តើម ( 15 pts )**

ក. លំនាំបញ្ហា ( 7 pts )

ខ. ចំណូលបញ្ហា ( 4 pts )

គ. ចំណោទបញ្ហា ៖ តើពុទ្ធោវាទខាងលើមានខ្លឹមសារអប់រំដូចម្តេចខ្លះ ? ( 4 pts )

2. **តួសេចក្តី ( 85 pts )**

ក. ឃ្លាភ្ជាប់សេចក្តី ( 2 pts )

ខ. ពន្យល់ពាក្យគន្លឹះ ( 4 pts )

- មុសាវាទ
- អាទិ៍
- បាបកម្ម

